**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# បទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឆា រស្មី**

**ជា ដារ៉ា**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# **សេចក្តីថ្លែងអំណរគុណ**

ក្រុមយើងខ្ញុំបាទ **ជា ដារ៉ា** និង **ធា រស្មី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៥ ២០១៩។

**សូមគោរពលំអោនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញុតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖**

លោកឪពុក **ឃឹម ពុំ** លោកឪពុក **ធៀ ពៅ**

អ្នកម្តាយ **ជា មួយលី** អ្នកម្តាយ **ធឹង ស៊ីម**

ដែលបានផ្តល់កំណើត និងខិតខំចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅ និងផ្តល់ដំបូន្មានល្អៗជួយជំរុញលើកទឹកចិត្តឲ្យកូនស្រឡាញ់ពេញចិត្តចំពោះការសិក្សា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ជាពិសេស មុខវិជ្ជាដែលសង្គមត្រូវការនាបច្ចុប្បន្ននេះ ដល់កូនតាំងពីពេលកូននៅជាកុមារភាពរហូតលុះដល់កូនធំពេញវ័យ និងបានទទួលការបណ្តុះបណ្តាលតាំងពីថ្នាក់បឋមសិក្សារហូតឈានដល់កម្រិតថ្នាក់បរិញ្ញាបត្រនេះ។ លោកទាំងពីរបានព្យាយាមទាំងកម្លាំងកាយ និងកម្លាំងចិត្តជួយទំនុកបម្រុងគ្រប់បែបយ៉ាងទាំងបញ្ញា និងស្មារតី ដើម្បីអោយកូនមានអនាគតភ្លឺស្វាង និងអភិវឌ្ឍខ្លួនក្លាយជាកូនល្អ ពលរដ្ឋល្អ នៅក្នុងសង្គមជាតិ។

ចំពោះលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកសាស្ត្រាចារ្យបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្តល់នូវគំនិត និងយោបល់ល្អៗ ក្នុងការកែសម្រួល នូវកំហុសខុសឆ្គងចំពោះការសរសេរសារណារបស់ក្រុមយើងខ្ញុំកន្លងមក រហូតសម្រេចបាននូវស្នាដៃសារណាមួយនេះឡើង។

ជាចុងក្រោយក្រុមយើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធពរជ័យដល់វត្ថុសក្តិសិទ្ធិក្នុងលោកតាមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ អោយជួបតែពុទ្ធិពរទាំង៥ប្រការគឺ អាយុ វណ្ណ សុខ: ពល: និងកុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៥-២០១៩ អស់រយៈពេល៥ឆ្នាំកន្លងមក ដោយការខិតខំសិក្សារៀនសូត្រ និងការផ្តល់ដំបូន្មានល្អៗពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ នៅក្នុងសាកលវិទ្យាល័យបានធ្វើឲ្យយើងខ្ញុំទាំងពីររូប ទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **បទល្មើសព្រហ្មទណ្ឌ** ។

ក្រុមយើងខ្ញុំពិតជាមានសេចក្តីសោមនាស់រីករាយណាស់ ដែលបានសរសេរ និងរៀបរៀងសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **បទល្មើសព្រហ្មទណ្ឌ** ក្រោមការណែនាំពីលោកគ្រូសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចែករំលែកនូវចំនេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់ក្រុមយើងខ្ញុំ។ សៀវភៅនេះស្រាវជ្រាវប្រមូលផ្តុំនឹងចងក្រងនូវខ្លឹមសារ ដែលជាវិធានច្បាប់សម្រាប់ធ្វើការសិក្សាទៅលើផ្នែកទ្រឹស្តី និងធ្វើការឆ្លុះបញ្ចាំងការអនុវត្តជាក់ស្តែងរបស់ស្ថាប័នមានសមត្ថកិច្ច។ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌវាបានបង្កើតជាឧបករណ៍គតិយុត្តមូលដ្ឋានមួយ សំរាប់ដំណើរការរឿងក្តីព្រហ្មទណ្ឌ តុលាការព្រហ្មទណ្ឌ និងផ្តល់ភាពយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ច្បាប់ព្រហ្មទណ្ឌពិតជាមានសារៈសំខាន់ណាស់ សំរាប់កំណត់អំពីអត្ថិភាពនៃបទល្មើស។

ការធ្វើសារណាមួយនេះ គឺក្នុងគោលបំណងជួយផ្សព្វផ្សាយពីវិស័យច្បាប់នៅកម្ពុជា និងអាចផ្តល់ជាជំនួយស្មារតីដល់ប្អូនៗ និស្សិតជំនាន់ក្រោយៗទៀត ដើម្បីបង្កើននូវចំណេះដឹងក្នុងការយល់ដឹងអំពីច្បាប់អោយកាន់តែទូលំទូលាយជាងនេះទៅទៀត។

ជាចុងក្រោយក្រុមយើងខ្ញុំ សង្ឃឹមថា ការខិតខំប្រឹងប្រែងធ្វើសារណាមួយនេះ នឹងជួយផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្អូនៗនិស្សិតជំនាន់ក្រោយៗទៀត ក្នុងការធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងច្បាប់។ សូមអរគុណ!

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖ សញ្ញាណទូទៅនៃបទល្មើស** ........ ៣

១.១ និយមន័យ ........ ៣

១.២ ភាពខុសប្លែកគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្សេងៗទៀត ........ ៣

១.២.១ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី ........ ៣

១.២.២ ការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ ........ ៤

**ជំពូកទី២៖ ធាតុផ្សំនៃបទល្មើស** ........ ៦

២.១ ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់ ........ ៦

២.១.១ គោលការណ៍នីត្យានុកូលភាព ........ ៦

ក. នីត្យានុកូលភាពនៃបទល្មើស ........ ៧

ខ. នីត្យានុកូលភាពនៃទោស ........ ៧

២.១.២ ផលវិបាកនៃគោលការណ៍នីត្យានុកូលភាព ........ ៧

២.១.៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ........ ៨

ក. ការបកស្រាយច្បាប់ព្រហ្មទណ្ឌ ........ ៨

ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល ........ ៩

ខ.១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ........ ៩

គ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងដែនដី ........ ១១

២.១.៤ ការត្រួតពិនិត្យមើលនីត្យានុកូលភាពនៃច្បាប់ព្រហ្មទណ្ឌ ........ ១៤

២.២ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ ........ ១៤

២.២.១ បទល្មើសបានសម្រេច ........ ១៤

ក. បទល្មើសសកម្ម ........ ១៤

ក.១ បទល្មើសសម្ភារៈ ........ ១៥

ក.២ បទល្មើសរូបភាព ........ ១៥

ខ. បទល្មើសអកម្ម ........ ១៦

២.២.២ បទល្មើសមិនបានសម្រេច ........ ១៦

ក. លក្ខខណ្ឌនៃអំពើប៉ុនប៉ងត្រូវមានទោស ........ ១៦

ខ. ការដាក់ទណ្ឌកម្មលើការប៉ុនប៉ង ............................................................. ១៧
ខ.១ ចំពោះបទឧក្រិដ្ឋ ............................................................. ១៧
ខ.២ ចំពោះបទមជ្ឈិម ............................................................. ១៧
ខ.៣ ចំពោះបទលហុ ............................................................. ១៧
គ. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស ............................................................. ១៧
គ.១ ដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស ............................................................. ១៨
គ.២ ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស ............................................................. ១៨
គ.៣ ដំណាក់កាលនៃការចាប់ផ្ដើមប្រព្រឹត្តបទល្មើស ............................................................. ១៩
គ.៤ ដំណាក់កាលនៃការសម្រេចបទល្មើស ឬបទល្មើសប៉ុនប៉ង ............................................................. ១៩
២.៣ ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ ............................................................. ១៩
២.៣.១ អំពីកំហុស ............................................................. ១៩
ក. កំហុសដោយចេតនា ............................................................. ២០
ខ. កំហុសដោយអចេតនា ............................................................. ២០
២.៣.២ មូលហេតុ ឬគំនិតផ្ដួចផ្ដើមបទល្មើស ............................................................. ២០
២.៣.៣ គោលដៅនៃការប្រព្រឹត្តបទល្មើស ............................................................. ២០
**ជំពូកទី៣៖ ចំណាត់ថ្នាក់នៃបទល្មើស** ............................................................. ២២
៣.១ ការបែងចែករវាងបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ ............................................................. ២២
៣.១.១ លក្ខណៈវិនិច្ឆ័យនៃការបែងចែក ............................................................. ២២
ក. បទឧក្រិដ្ឋ ............................................................. ២២
ខ. បទមជ្ឈិម ............................................................. ២៣
គ. បទលហុ ............................................................. ២៣
៣.១.២ ផលប្រយោជន៍នៃការបែងចែក ............................................................. ២៣
ក. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ............................................................. ២៣
ខ. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី ............................................................. ២៤
គ. ផលប្រយោជន៍ទាក់ទងនឹងការកំណត់បទល្មើសប៉ុនប៉ង ............................................................. ២៤
ឃ. ផលប្រយោជន៍ទាក់ទងនឹងការកំណត់ការផ្ដើមគំនិត និងការសមគំនិត ............................................................. ២៥
៣.២ ការបែងចែករវាងបទល្មើសដោយចេតនា និងបទល្មើសអចេតនា ............................................................. ២៥
៣.២.១ បទល្មើសដោយចេតនា ............................................................. ២៥

៣.២.២ បទល្មើសដោយអចេតនា ........................................................................................ ២៥
៣.៣ ការបែងចែករវាងបទល្មើសនយោបាយ បទល្មើសយោធា និងបទល្មើសភេរវកម្ម ........... ២៦
៣.៣.១ បទល្មើសនយោបាយ ................................................................................................ ២៦
៣.៣.២ បទល្មើសយោធា ........................................................................................................ ២៦
៣.៣.៣ បទល្មើសភេរវកម្ម ..................................................................................................... ២៦
៣.៤ ផលប្រយោជន៍នៃការបែងចែកបទល្មើស (ទាក់ទងនឹងសមត្ថកិច្ច)...................................២៧
៣.៥ ចំណាត់ថ្នាក់ទៅតាមប្រភេទនៃអំពើជាសម្ភារៈ ...................................................................២៧
៣.៥.១ បទល្មើសសកម្ម ........................................................................................................២៧
៣.៥.២ បទល្មើសអកម្ម.......................................................................................................... ២៨
**ជំពូកទី៤ ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**......... ២៩
៤.១ ការទទួលខុសត្រូវព្រហ្មទណ្ឌ ........................................................................................... ២៩
៤.១.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ........................................................... ២៩
ក. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន ...................................................................... ២៩
ខ. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ....................................................................៣១
ខ.១ វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស ...........................................................៣១
ខ.២ ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន ............................................................................. ៣២
៤.១.២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ..............................................................៣៣
ក. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល..............................................៣៥
ក.១ អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ..............................................................៣៥
ក.២ បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល ..............................................៣៥
ក.៣ ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល ...........................................................៣៥
ខ. ការដាក់ទណ្ឌកម្មលើនីតិបុគ្គល.....................................................................................៣៥
៤.២ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ .......................................................................................៣៦
៤.២.១ មូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ..............................................................៣៦
ក. វិបល្លាសស្មារតី ............................................................................................................ ៣៧
ខ. កម្លាំង ឬការបង្ខំ ......................................................................................................... ៣៧
ខ.១ ការបង្ខំលើរូបកាយ ................................................................................................ ៣៧
ខ.២ ការបង្ខំលើផ្លូវចិត្ត ....................................................................................................៣៨

គ. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ..........៣៨
គ.១ ការអនុញ្ញាតដោយច្បាប់..........៣៨
គ.២ ការអនុញ្ញាតដោយអាជ្ញាធរ..........៣៨
គ.៣ អាជ្ញាធរស្របច្បាប់..........៣៨
គ.៤ បញ្ជាស្របច្បាប់..........៣៩
ឃ. ការការពារស្របច្បាប់ ..........៣៩
ឃ.១ លក្ខខណ្ឌនៃការការពារស្របច្បាប់ ..........៣៩
ឃ.១.១ ការឈ្លានពាន..........៣៩
ឃ.២.២ ការការពារឈ្លានពាន .......... ៤០
ង. ស្ថានភាពចាំបាច់.......... ៤០
ង.១ គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន .......... ៤១
ង.២ ការការពារជាចាំបាច់ .......... ៤១
ង.៣ ការការពារដែលគ្មានវិសមាមាត្រជាមួយនឹងទម្ងន់គ្រោះថ្នាក់ .......... ៤១
**សេចក្ដីសន្និដ្ឋាន**.......... ៤២
**អនុសាសន៍**..........៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

ជាការពិតណាស់នៅពេលដែលប្រទេសជាតិមានភាពរីកចម្រើន មនុស្សត្រូវការរបស់របរគ្រប់បែបយ៉ាងដើម្បីបំពេញនូវសេចក្ដីត្រូវការរបស់ពួកគេ ដើម្បីរស់នៅក្នុងសង្គមមួយប្រកបដោយភាពសុខស្រួល។ បើទោះបីជាមនុស្សរស់នៅដោយភាពសុខស្រួលក៏ដោយ ប្រសិនបើផ្លូវស្វែងរករបស់របរគ្រប់បែបយ៉ាងទៅរកភាពសុខស្រួលនោះធ្វើអោយប៉ះពាល់ដល់អ្នកដ៏ទៃ ច្បាស់ណាស់ថាការរស់នៅក្នុងសង្គមមួយ គឺមនុស្សមិនអាចគេចផុតពីការទំនាស់បានឡើយ។ ដូច្នេះហើយបានជានៅក្នុងប្រទេសនីមួយៗមានច្បាប់សម្រាប់ការពារនៅពេលដែលមានបទល្មើសមួយកើតឡើង។

ក្រមព្រហ្មទណ្ឌ បានផ្ដល់នូវនិយមន័យពីបទល្មើសព្រហ្មទណ្ឌថា ជាអំពើទាំងឡាយណាដែលបានធ្វើឲ្យខូចសណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ ឬអំពើប្រឆាំងនឹងមនុស្ស អំពើដែលប៉ះពាល់នៃបូរណភាពនៃបុគ្គល ប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ សេរីភាព ឬសិទ្ធិរបស់មនុស្ស ឬអំពើបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃដូចជាៈ អំពើលួច ឆក់ ប្លន់ជាដើម។ ជាក់ស្ដែងក្នុងករណីវិវាទនីមួយៗនៅក្នុងសង្គម ច្រើនកើតឡើងដោយសារទំនាស់។ ទំនាស់កើតឡើងរវាងភាគីពីរនាក់ ឬច្រើននាក់ ដែលមិនសុខចិត្តនឹងគ្នា ដែលរួមមានប្រជាពលរដ្ឋ និងប្រជាពលរដ្ឋរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ឬរវាងអាជ្ញាធរ និងអាជ្ញាធរ រហូតដល់បង្កឲ្យមានជារឿងព្រហ្មទណ្ឌ។ ដូច្នេះក្នុងរឿងព្រហ្មទណ្ឌត្រូវមានបណ្ដឹងពីរ គឺបណ្ដឹងព្រហ្មទណ្ឌ ឬបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី។ “**ទំនាស់**” ត្រូវបានដោះស្រាយតាមផ្លូវច្បាប់ ដែលមានស្ថាប័នតុលាការជាអ្នកអនុវត្តដោយតម្លាភាព, អព្យាក្រឹត្យ, និងមិនលំអៀង។ ក្នុងស្ថាប័នតុលាការត្រូវមានមន្ត្រីតុលាការជាអ្នកធ្វើការស៊ើបសួរ និងអង្កេតរកភស្តុតាង។ មន្ត្រីតុលាការរួមមានចៅក្រម, ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា ដែលជាអ្នកមានសិទ្ធិសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់ចំពោះមុខតុលាការ ដោយឈរលើការវិនិច្ឆ័យផ្អែកលើអង្គហេតុ និងអង្គច្បាប់ប្រកបដោយឯករាជ្យ អព្យាក្រឹត្យ និងសុចរិតភាព។

ការសម្រេចយកប្រធានបទមួយនេះមកសរសេរ គឺក្រុមយើងខ្ញុំយល់ឃើញថាវាមានសារៈសំខាន់ណាស់ នៅក្នុងសង្គមទាំងផ្នែកសិក្សា និងការអនុវត្ត។ អ្វីដែលជាកម្មវត្ថុនៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺចង់បង្ហាញពីបទល្មើសព្រហ្មទណ្ឌដែលក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថាការអនុវត្តទោសមានពីរ គឺទោស“**ដាក់ពន្ធនាគារ**” និងទោស“**ពិន័យជាប្រាក់**”។ បើទោះបីជាយ៉ាងណាក៏ដោយ ក៏ទោសទាំងពីរនេះអាចអនុវត្តព្រមគ្នា ចំពោះតែបទល្មើសមជ្ឈិមប៉ុណ្ណោះ។ បទល្មើសក្រៅពីនេះ អនុវត្តទោសតែមួយក្នុងចំណោមទោសទាំងពីរ ទៅតាមបទល្មើសដែលបានប្រព្រឹត្ត។

ការស្រាវជ្រាវទៅលើប្រធានបទនេះបានសង្កត់ធ្ងន់ទៅលើនិយមន័យ ធាតុផ្សំបទល្មើស និង ការទទួលខុសត្រូវនៅក្នុងរឿងព្រហ្មទណ្ឌ។ បទល្មើស គឺជាអំពើខុសនឹងសីលធម៌សង្គម ដែលផ្តល់ផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងបង្កឲ្យមានព្យសនកម្មគួរឲ្យកត់សម្គាល់សម្រាប់សង្គម។ អំពើដែលអាចចាត់ទុកថាជាបទល្មើសបាន លុះត្រាតែមានធាតុផ្សំ៣យ៉ាងគឺ៖

**ធាតុនីត្យានុកូល៖** គឺមានន័យថាដើម្បីកំណត់អំពើណាមួយថាជាបទល្មើសបាន គឺលុះត្រាតែមានច្បាប់ចែងច្បាស់លាស់។

**ធាតុសត្យានុម័ត៖** គឺជាការប្រព្រឹត្តអំពើល្មើសនឹងច្បាប់ និង មានផលវិបាក ឬ លទ្ធផលដែលកើតឡើងពីអំពើល្មើសនោះពិតប្រាកដ។

**ធាតុអន្តោម័ត៖** គឺជាចិត្តគំនិតខាងក្នុងរបស់ជនល្មើស ដែលវាស្តែងមកខាងក្រៅតាមរយៈ ធាតុសត្យានុម័តដូចជា: កាយវិការ ឬអំពើប្រព្រឹត្តរបស់ជនល្មើស។

សារណានេះបានរៀបរៀង ដោយធ្វើការសិក្សាស្រាវជ្រាវ ធ្វើការប្រមូលនូវព័ត៌មានទាំងឡាយដែលក្នុងនោះរួមមានដូចជា: ឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណាមួយនេះ ដើម្បីអោយមានភាពត្រឹមត្រូវនឹងច្បាស់លាស់។ ការដកស្រង់ចេញមកពីប្រភពល្អៗ ក៏ដូចជាការបកស្រាយរបស់នីតិករ, អ្នកដែលមានបទពិសោធន៍នៅក្នុងវិស័យច្បាប់, យោបល់របស់អ្នកជំនាញផ្នែកច្បាប់ និងច្បាប់មួយចំនួន។ ដើម្បីឆ្លើយតបទៅនឹងប្រធានបទខាងលើ គឺយើងបានធ្វើការបែងចែកជា៤ជំពូកធំៗ គឺរួមមាន៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃបទល្មើស**

**ជំពូកទី២៖ ធាតុផ្សំនៃបទល្មើស**

**ជំពូកទី៣៖ ចំណាត់ថ្នាក់នៃបទល្មើស**

**ជំពូកទី៤៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

# ជំពូកទី ១
# សញ្ញាណទូទៅនៃបទល្មើស

# ជំពូកទី១៖ សញ្ញាណទូទៅនៃបទល្មើស

## ១.១ និយមន័យ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយជាកំហុសរបស់ចារីផ្ទាល់។ ម្យ៉ាងវិញទៀត បទល្មើសអាចត្រូវចាត់ទុកថាជាបាតុភូតអសកម្ម ក្នុងជីវភាពរស់នៅផងដែរ ដោយហេតុថាបទល្មើសបានជះឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់សង្គម ដល់សេរីភាពរបស់ពលរដ្ឋ។

ជាធម្មតាគេចាត់ទុកអំពើមួយ គឺជាបទល្មើសបាន លុះត្រាតែអំពើនោះបានបង្ហាញនូវគ្រោះថ្នាក់ដល់សង្គមដែលច្បាប់ការពារ។ ជាទូទៅបទល្មើស គឺជាអំពើខុសនឹងសីលធម៌សង្គម និងបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងបង្កឲ្យមានព្យសនកម្មដល់សង្គម។ តាមការពិតទៅ មិនមែនមានតែបទល្មើសព្រហ្មទណ្ឌ ដែលបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គមទេ គឺនៅមានអំពើមួយចំនួនទៀត ដែលជាអំពើបង្កឲ្យមានគ្រោះថ្នាក់ដែរ ក៏ប៉ុន្តែមិនត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌទេ តែគេចាត់ទុកថាជាកំហុសរដ្ឋប្បវេណី ហើយចារីត្រូវដាក់ទណ្ឌកម្មឲ្យបង់ជាសំណង និងជម្ងឺចិត្តតែប៉ុណ្ណោះ។

## ១.២ ភាពខុសប្លែកគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្សេងៗទៀត

### ១.២.១ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី

អំពើល្មើសផ្នែករដ្ឋប្បវេណី គឺមានប្រភពមកពីបទបញ្ញត្តិនៃមាត្រា១២១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨ ដែលចែងថា ជនណាធ្វើឲ្យមានការខូចខាតដល់អ្នកដទៃដោយកំហុសរបស់ខ្លួន ជននោះត្រូវជួសជុលការខូចខាត។ រីឯបទល្មើសព្រហ្មទណ្ឌវិញ គឺត្រូវតែជាអំពើដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ថាជាបទល្មើសព្រហ្មទណ្ឌ។

សម្រាប់អំពើរដ្ឋប្បវេណីវិញ ព្យសនកម្ម គឺជាកត្តាចាំបាច់ណាស់ ដើម្បីអាចអោយចៅក្រមដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តបាន។ ផ្ទុយទៅវិញការបង្កើតជាបទល្មើសព្រហ្មទណ្ឌពុំសុទ្ធតែទាមទារឲ្យមានព្យសនកម្មទេដូចជា: បទល្មើសជួញដូរគ្រឿងញៀន ការបើកបរល្បឿនខុសច្បាប់ជាដើម ការបង់សំណងជម្ងឺចិត្ត ជាទណ្ឌកម្មសម្រាប់អំពើល្មើសរដ្ឋប្បវេណី និងជាទណ្ឌកម្មដែលផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ។ ប្រាក់ពិន័យ គឺជាចំណូលថវិការបស់រដ្ឋ រីឯប្រាក់សំណងជម្ងឺចិត្ត គឺត្រូវបានទៅជនរងគ្រោះ។ អំពើល្មើសផ្នែករដ្ឋប្បវេណីខ្លះថ្វីត្បិតតែជាអំពើខុសឆ្គង ប៉ុន្តែពុំមែនជាបទល្មើសទេ។ **ឧទាហរណ៍:** ការធ្វើឲ្យខូចខាតទ្រព្យរបស់អ្នកដទៃដោយអចេតនា។ ផ្ទុយទៅវិញអំពើមួយអាចត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌផង អំពើល្មើសផ្នែករដ្ឋប្បវេណីផង គឺរួមមានដូចជា: អំពើឃាតកម្ម ឬអំពើហិង្សាដោយចេតនាដល់តតិយជនជាដើម។ ក្នុងករណីបែបនេះអំពើ

ល្មើសនាំឲ្យមានបណ្ដឹងពីរប្រភេទគឺៈ **បណ្ដឹងអាជ្ញា**[1] និង **បណ្ដឹងរដ្ឋប្បវេណី**[2] ។

### ១.២.២ ការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ

គឺជាអំពើធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សមូហភាពនៃក្រុមសង្គមណាមួយដូចជាៈ ពេទ្យ មេធាវីជាដើម ដោយអំពើនោះមិនត្រូវបានកំណត់ឲ្យច្បាស់លាស់ជាទូទៅទេ។ **ឧទាហរណ៍:** មាត្រា ៥៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ បានចែងថាៈ ត្រូវទទួលទណ្ឌកម្ម ជាបទវិន័យចំពោះ មេធាវីណាដែលប្រព្រឹត្តល្មើស និងវិធានវិជ្ជាជីវៈប្រកបវិជ្ជាជីវៈរបស់ខ្លួន។ ការកំណត់យ៉ាងដូច្នេះបាន បង្ហាញឲ្យឃើញថា អំពើល្មើសផ្នែកពិន័យសម្រាប់វិជ្ជាជីវៈមេធាវី ពុំត្រូវបានបញ្ជាក់ឲ្យច្បាស់ជាមុន ដូចជាៈ បទល្មើសព្រហ្មទណ្ឌទេ ព្រោះថាអំពើប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវីជាសញ្ញាមួយ ទូលំទូលាយណាស់។

ផ្ទុយទៅវិញបទល្មើសព្រហ្មទណ្ឌទោះបីជាមានច្រើនយ៉ាងណាក៏ដោយ ក៏សុទ្ធសឹងជាអំពើ ដែលច្បាប់បានកំណត់យ៉ាងច្បាស់លាស់ជាមុនរួចស្រេចអស់ហើយ។ មានន័យថាអំពើណាដែល ច្បាប់ពុំបានចែងថាជាបទល្មើសព្រហ្មទណ្ឌទេ គឺពុំអាចចាត់ទុកថាអំពើនោះ ជាបទល្មើសព្រហ្មទណ្ឌ ឡើយ ដោយផ្អែកតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស។ អំពើល្មើសផ្នែកវិន័យធ្វើឲ្យប៉ះ ពាល់តែផ្នែកណាមួយនៃសង្គមតែប៉ុណ្ណោះ។ ពោលគឺក្រុមសង្គមដែលជនប្រព្រឹត្តល្មើសស្ថិតនៅ។ ប៉ុន្តែបទល្មើសព្រហ្មទណ្ឌវិញ ជាអំពើដែលប៉ះពាល់ដល់សង្គមជាទូទៅ។ ការដាក់ទណ្ឌកម្មលើអំពើ ល្មើសខាងវិន័យ គឺត្រូវធ្វើដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយដូចជាៈ ក្រុមប្រឹក្សា មេធាវីសម្រាប់ការដាក់វិន័យមេធាវី ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់ការដាក់វិន័យចៅក្រម ជាដើម។ ចំណែកឯការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌវិញ គឺជាសមត្ថកិច្ចរបស់សាលាជម្រះក្តីនៃព្រះ រាជាណាចក្រកម្ពុជា ហើយទណ្ឌកម្មអាចមានលក្ខណៈធ្ងន់ធ្ងររហូតដល់ការដាក់ពន្ធនាគារអស់មួយ ជីវិតទៀតផងដូចជាៈ បំណែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណីដែលការ បែងចែករវាងបទល្មើសផ្នែកវិន័យ និងបទល្មើសព្រហ្មទណ្ឌ គឺវាឆ្លុះបញ្ចាំងឲ្យឃើញថា ក្នុងករណីខ្លះ អំពើមួយត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែកវិន័យទេ។

**ឧទាហរណ៍:** អំពើលួចប្រព្រឹត្តដោយជនអនាថាម្នាក់។ ពេលខ្លះអំពើណាមួយត្រូវចាត់ទុកជាអំពើ ល្មើសផ្នែកវិន័យ ប៉ុន្តែពុំត្រូវបានចាត់ចូលជាបទល្មើសព្រហ្មទណ្ឌឡើយ។ អំពើមួយចំនួនត្រូវចាត់

[1] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ **បណ្ដឹងអាជ្ញា** មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យ ឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះ តាមច្បាប់កំណត។

[2] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ **បណ្ដឹងរដ្ឋប្បវេណី** មានគោលបំណងធ្វើឲ្យបានជួសជុលការខូចខាត ដែល បណ្ដាលមកពី អំពើល្មើស ដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឲ្យអ្នករងគ្រោះ បានទទួលសំណងជម្ងឺចិត្តធួន ល្មម នឹងព្យសនកម្ម ដែលខ្លួនបានទទួល។

ទុកជាអំពើល្មើសផ្នែកវិន័យផង និងជាបទល្មើសព្រហ្មទណ្ឌផង រួមមានដូចជា: ឃាតកម្មប្រព្រឹត្ត ដោយវេជ្ជបណ្ឌិតម្នាក់ ទៅលើអតិថិជនរបស់ខ្លួន ឬការរំលូតកូនដោយល្មើស និងច្បាប់ស្តីពីការរំលូតកូន ឆ្នាំ១៩៩៧ ។ល។ អំពើដែលច្បាប់បានកំណត់ថាជាបទល្មើស គឺមានច្រើនណាស់ ដែលមិនអាចរៀបរាប់ឲ្យអស់សេចក្តីបាននោះទេ។ មិនមែនមានតែក្រមព្រហ្មទណ្ឌទេ ដែលកំណត់អំពីបទល្មើស គឺនៅមានច្បាប់ជាច្រើនផ្សេងៗទៀត ក៏បានកំណត់បទល្មើសដែរ ហើយជាងនេះទៅទៀត បទដ្ឋានគតិយុត្ត ដែលចេញដោយអង្គការនីតិប្រតិបត្ត ក៏អាចកំណត់ពីបទល្មើសបទលហុបានដែរ។[3] ដូច្នេះ ដើម្បីអាចរាប់បទល្មើសទាំងអស់បាន លុះត្រាតែពិនិត្យឲ្យបានគ្រប់ច្បាប់ និងបទដ្ឋានគតិយុត្តទាំងអស់នោះទើបអាចដឹងបាន។ ក្នុងករណីនេះ គឺគេអាចធ្វើការបែងចែកចំណាត់ថ្នាក់បទល្មើសទៅតាមប្រភេទនៃបទល្មើសនីមួយៗបាន។

[3] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១។

# ជំពូកទី ២
# ធាតុផ្សំនៃបទល្មើស

# ជំពូកទី២៖ ធាតុផ្សំនៃបទល្មើស

ជាគោលការណ៍ច្បាប់បានចែងក្នុងមាត្រា២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ការចោទប្រកាន់ និងការផ្តន្ទាទោសជនណា ឬបុគ្គលណាមួយបាន គឺលុះត្រាតែតុលាការបានរកឃើញ និងបានប្រកាសពិរុទ្ធភាពដាក់បន្ទុកលើជននោះជាមុនសិន។[4] ការប្រកាសពិរុទ្ធភាពលើជនណាម្នាក់ ឬបុគ្គលណាមួយអាចអនុវត្តបាន គឺលុះត្រាតែអំពើដែលប្រព្រឹត្តនោះមានធាតុផ្សំគ្រប់គ្រាន់ដែលតុលាការអាចប្រកាសទោសលើជននោះ ឬបុគ្គលនោះបាន។ ផ្ទុយទៅវិញ ប្រសិនបើអំពើដែលប្រព្រឹត្តនោះពុំមានធាតុផ្សំគ្រប់គ្រាន់ ឬពុំមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ឬបុគ្គលណាមួយសោះទេ តាមគោលការណ៍តុលាការមិនអាចប្រកាសផ្តន្ទាទោសលើជននោះ ឬបុគ្គលនោះបានទេ។ ដោយហេតុថាជននោះ ឬបុគ្គលដែលត្រូវចោទប្រកាន់តាមផ្លូវតុលាការនោះ ក៏ត្រូវតែបានរួចផុតពីបទចោទប្រកាន់តាមផ្លូវច្បាប់ដែលមានចែងក្នុងមាត្រា៣៥០ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។[5]

## ២.១ ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់

មានន័យថា ដើម្បីកំណត់អំពើណាមួយថាជាបទល្មើសបាន គឺលុះត្រាតែមានច្បាប់ចែងច្បាស់លាស់។ ប្រសិនបើច្បាប់ពុំបានចែងថា អំពើនេះ ឬអំពើនោះជាបទល្មើសនោះទេ គឺយើងមិនអាចថាជាបទល្មើសបានឡើយ។ ហេតុនេះហើយ ទើបបានជាគេឃើញមានគោលការណ៍បារាំងមួយបាននិយាយថា គ្មានបទល្មើសណាមួយដែលច្បាប់ពុំបានចែងទេ។ ហើយលើសពីនេះទៅទៀតគេក៏ឃើញមានគោលការណ៍បារាំងមួយទៀតបាននិយាយថាអ្វីៗទាំងអស់ ដែលគេមិនបានហាមឃាត់ គឺមានន័យថាគេអនុញ្ញាតឲ្យហើយ។[6]

### ២.១.១ គោលការណ៍នីត្យានុកូលភាព

**ធាតុនីត្យានុកូល** គឺសំដៅទៅលើអត្ថបទច្បាប់ដែលបញ្ញត្តិអំពើណាដែលចាត់ទុកថាជាបទល្មើស និងកំណត់អំពីទោសដែលត្រូវទទួលរង។ ក្នុងស្មារតីនៃការកំណត់បទល្មើសច្បាប់គ្រាន់តែជាធាតុបឋមតែប៉ុណ្ណោះ។ មានន័យថា ធាតុនីត្យានុកូលធ្វើឲ្យមាននីត្យានុកូលភាពនៃបទល្មើស និងទោសដូចដែលមានចែង ក្នុងមាត្រា៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានបញ្ញត្តិថា មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែង ក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។

---

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៣។

[5] សេង ស៊ីវិត្ថា, នីតិព្រហ្មទណ្ឌខ្មែរ, (ភ្នំពេញ,២០១០)។

[6] ហ៊ាង ឡេង , នីតិព្រហ្មទណ្ឌ, (ភ្នំពេញ,២០១០)។

មានតែទោសដែលមានចែង ក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន។[7] គោលការណ៍នីត្យានុកូលភាពត្រូវបានទទួលស្គាល់ដោយ **លិខិតតុបករណ៍អន្តរជាតិ**[8] ដែលមានតម្លៃជារដ្ឋធម្មនុញ្ញតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

**គោលការណ៍នីត្យានុកូលភាពនេះរួមមាន៖**

**ក. នីត្យានុកូលភាពនៃបទល្មើស**

មានន័យថា អំពើណាមួយដែលគេអាចចាត់ទុកថាជាបទល្មើសបាន គឺលុះត្រាតែអំពើនោះមានចែងយ៉ាងច្បាស់លាស់ក្នុងច្បាប់ថាជាបទល្មើស បើមិនដូច្នោះទេតុលាការមិនអាចផ្តន្ទាទោសជនប្រព្រឹត្តនោះបានឡើយ ហេតុនេះហើយបានជាគេឃើញមានគោលការណ៍មួយបាននិយាយថា គ្មានបទល្មើសណាមួយដែលច្បាប់មិនបានចែងនោះឡើយ។[9]

**ខ. នីត្យានុកូលភាពនៃទោស**

មានន័យថា ដើម្បីយកទោសណាមួយទៅផ្តន្ទាទោសលើបុគ្គលណាមួយបាន លុះត្រាតែទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូច្នោះទេ គឺគេមិនអាចអនុវត្តទោសទៅលើបុគ្គលនោះបានទេ។ ហេតុនេះហើយបានជាគេឃើញមានគោលការណ៍មួយបាននិយាយថា គ្មានទោសណាដែលច្បាប់មិនបានចែងនោះឡើយ។

**២.១.២ ផលវិបាកនៃគោលការណ៍នីត្យានុកូលភាព**

- ការបកស្រាយជាក់លាក់ត្រឹមត្រូវនៃនីតិព្រហ្មទណ្ឌ គឺដើម្បីឲ្យចៅក្រមអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ហើយការផ្តន្ទាទោសត្រូវតែឲ្យចំបទល្មើសដែលមានចែងក្នុងច្បាប់ ។
- ការបកស្រាយតាមពាក្យពេចន៍ គឺជាការបកស្រាយច្បាប់មួយប្រភេទដោយផ្អែកលើពាក្យពេចន៍ដែលបានចែងច្បាស់លាស់ក្នុងច្បាប់។
- ការបកស្រាយតាមស្មារតីនៃអង្គប្រជុំរបស់រដ្ឋសភា គឺជាការបកស្រាយមួយបែបដោយពឹងផ្អែកលើការពិភាក្សាដេញដោលរបស់វាគ្មិន នៅពេលបញ្ចេញមតិក្នុងការអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នានា។
- ការបកស្រាយតាមគោលការណ៍ប្រហាក់ប្រហែល គឺភាគច្រើនគេអនុវត្តនៅប្រទេសប្រកាន់របបសង្គមនិយម (កុំម្មុយនីស្ត) ហេតុនេះហើយបានជាគេឃើញមានច្បាប់នានា

[7] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣។

[8] **លិខិតុបករណ៍អន្តរជាតិ** គឺជាលិខិតបទដ្ឋានអន្តរជាតិ ដែលបង្កើតឡើងរវាងរដ្ឋ និងរដ្ឋ ឬក៏រវាងរដ្ឋ និងអង្គការអន្តរជាតិ។

[9] ហ៊ាង ឡេង , នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ,២០១០)។

របស់ប្រទេសសង្គមនិយមច្រើនតែសរសេរខ្លីៗ មិនសូវច្បាស់លាស់ដោយគេសំអាងថា នៅពេលមានការមន្ទិលសង្ស័យ គឺគេតែងតែលើកយកគោលការណ៍នេះមកបកស្រាយ ។

ជាក់ស្តែងណាស់តាមគោលការណ៍ខាងលើ ដើម្បីអាចឲ្យគេចាត់ទុកថាជា អំពើណាមួយជាបទល្មើស ហើយត្រូវផ្តន្ទាទោសបាន លុះត្រាតែមានអត្ថបទច្បាប់បានចែងថា អំពើនោះជាបទល្មើស ហើយត្រូវទទួលទណ្ឌកម្មដែលច្បាប់បានកំណត់។ ដូច្នេះរាល់ការចោទប្រកាន់ និងការដាក់ទោសទាំងអស់ត្រូវតែផ្អែកលើច្បាប់។ គ្មានបទល្មើសព្រហ្មទណ្ឌទេ ប្រសិនបើគ្មានបទប្បញ្ញត្តិច្បាប់ចែងអំពីបទល្មើស ហើយគ្មានទោសទេ ប្រសិនបើគ្មានបទប្បញ្ញត្តិច្បាប់ចែងអំពីទោស។

**២.១.៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ**

ការអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺជាការសំដែងប្រតិកម្មរបស់សង្គមដែលឆ្លើយតបទៅនឹងជនល្មើស និងអំពើល្មើសក្នុងគោលដៅធានាឲ្យបាននូវភាពសុខស្ងប់ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ជូនដល់សង្គមទាំងមូល។

**ក.ការបកស្រាយច្បាប់ព្រហ្មទណ្ឌ**

ដើម្បីអាចអនុវត្តច្បាប់ព្រហ្មទណ្ឌឲ្យបានត្រឹមត្រូវ គឺត្រូវធ្វើការបកស្រាយឲ្យបានសមស្រប និងត្រឹមត្រូវជាដំណាក់កាល ដែលមិនអាចខ្វះបានមុននឹងឈានទៅរកការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ ហេតុនេះហើយ ទើបចៅក្រមមានកាតព្វកិច្ចផ្ទៀងផ្ទាត់ផ្គូរផ្គងដោយប្រុងប្រយ័ត្ន និងហ្មត់ចត់នូវច្បាប់ដែលចង្អុលបង្ហាញអំពីបទល្មើសអត្ថិភាពនៃទោស និងការត្រួតពិនិត្យរកមើលអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។ ការដកហូតសិទ្ធិសេរីភាពបុគ្គល ទោះក្នុងរយៈពេលណាមួយជាកំណត់ គឺតម្រូវឲ្យមានភាពច្បាស់លាស់អំពីនីត្យានុកូលភាពនៃអំពើ និងទោសដែលត្រូវអនុវត្តនោះ។ បើពុំនោះទេការដកហូតនោះនឹងធ្វើឡើងដោយរំលោភសិទ្ធិសេរីភាពបុគ្គល។

**ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងន័យទូទៅ៖** ក្នុងរឿងព្រហ្មទណ្ឌច្បាប់ ត្រូវតែបកស្រាយយ៉ាងតឹងរឹង។[10] មាត្រានេះ គឺចង់ចង្អុលបង្ហាញប្រាប់ទៅ ចៅក្រមទទួលបន្ទុកអនុវត្តច្បាប់ឲ្យធ្វើការផ្ទៀងផ្ទាត់ និងផ្គូរផ្គងដោយហ្មត់ចត់ និងប្រកបដោយការយកចិត្តទុកដាក់រវាងអង្គហេតុ និងអត្ថបទច្បាប់ព្រហ្មទណ្ឌមុននឹងសម្រេចអនុវត្តច្បាប់ព្រហ្មទណ្ឌទៅនឹងអង្គហេតុ។ ចៅក្រមមិនត្រូវយកច្បាប់មកអនុវត្តទេ ប្រសិនបើច្បាប់ចែងមិនច្បាស់លាស់ (វិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទ ) ហើយចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។[11] **សទិសភាព** គឺជាការប្រដូចអំពើណាមួយដែលច្បាប់មិនបានកំណត់ថាជាបទល្មើស។

[10] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥។
[11] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥។

រីឯការពង្រីកដែនអនុវត្ត គឺសំដៅទៅលើស្ថានភាពដែលថៅក្រមពង្រីកដែនអនុវត្តច្បាប់ ក្នុងករណីដូចជា: មាត្រា៣៨៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងអំពី បទបន្លំ ( ស៊ីមាំង ) នៅតាមគេហដ្ឋានឯកជន ដែលច្បាប់សំដៅទៅលើតែទីកន្លែងប្រកបអាជីវកម្ម។[12]

### ខ.ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល

#### ខ.១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

គោលការណ៍ច្បាប់មួយ គឺមានអនុភាពអនុវត្តតែក្នុងពេលអនាគត ពោលគឺចាប់បីថ្ងៃ ចូលជាធរមានរហូតដល់ពេលនិរាករណ៍កែប្រែ ឬជំនួសដោយច្បាប់ថ្មី។ តាមមាត្រា៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានបញ្ញត្តិថា ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យច្បាប់សព្វគ្រប់រួចហើយៗ ត្រូវបានព្រះមហាក្សត្រប្រកាសឲ្យប្រើត្រូវចូលជាធរមាននៅភ្នំពេញ គឺមានរយៈពេល**១០ ថ្ងៃគត់** ក្រោយថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេស គឺមានរយៈពេល **២០ ថ្ងៃគត់** ក្រោយប្រកាសឲ្យប្រើ។ ក៏ប៉ុន្តែបើច្បាប់នេះបានចែងជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមាន ភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឲ្យប្រើ។ ដូចនេះច្បាប់ក្នុងន័យទូទៅ និងច្បាប់ព្រហ្មទណ្ឌជាពិសេស អាចមានអនុភាពអនុវត្តតែទៅលើអំពើទាំងឡាយណា ដែលកើតក្រោយថ្ងៃ ចូលជាធរមានរបស់ខ្លួនតែប៉ុណ្ណោះ។ គោលការណ៍នេះគេឲ្យឈ្មោះថា "**គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ**" ។ គោលការណ៍នេះក៏ជាផលវិបាកនៃគោលការណ៍នីត្យានុកូលនៃបទល្មើស និងនៃទោសដែរ ព្រោះថានៅពេលដែលមិនមានច្បាប់ចែងទេនោះ គឺពុំមានបទល្មើសហើយពុំមានការផ្តន្ទាទោសនោះទេ។ គោលការណ៍នេះ គឺមានគោលដៅដើម្បីការពារសេរីភាពបុគ្គល មានន័យថា នៅពេលដែលពុំទាន់មានច្បាប់ហាមឃាត់ទេនោះ គឺបុគ្គលនោះមានសេរីភាពពេញលេញ ដើម្បីធ្វើជាសកម្មភាពណាមួយ ក៏ប៉ុន្តែគេសង្កេតឃើញថាមានអញ្ញត្រកម្មមួយចំនួនផងដែរ ចំពោះគោលការណ៍នេះ។

- ❖ **អញ្ញាត្រកម្ម**

អញ្ញាត្រកម្មបានដល់សម្មតិកម្មទាំងឡាយណាដែលក្នុងនោះ ច្បាប់ព្រហ្មទណ្ឌមួយអាចមានអានុភាពអនុវត្ត ចំពោះអំពើទាំងឡាយណាដែលបានកើតមុនការចូលជាធរមានរបស់ខ្លួន ឬក្នុងករណីដែលច្បាប់ព្រហ្មទណ្ឌត្រូវយកមកអនុវត្ត ភ្លាមៗ ភាពប្រតិសកម្ម ឬភាពត្រូវយកមកអនុវត្តភ្លាមៗនេះ គឺវាអាស្រ័យទាំងស្រុង ថាតើច្បាប់នោះ ជា**ច្បាប់សារធាតុ**.[13] **ឬ ច្បាប់នីតិវិធី**.[14]។

[12] សាស្ត្រាចារ្យ សែ វ៉េង ,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ,២០១៣)។

[13] **ច្បាប់សារធាតុ ឬ ច្បាប់ព្រហ្មទណ្ឌគ្រឹះ** គឺជាច្បាប់ ដែលកំណត់ពីបទល្មើស និងពីទោស ដែលត្រូវអនុវត្តលើបទល្មើស ព្រមទាំង លក្ខខណ្ឌ នៃការទទួលខុសត្រូវរបស់ចារី។

[14] **ច្បាប់នីតិវិធី ឬ ច្បាប់ព្រហ្មទណ្ឌទម្រង់** គឺជាច្បាប់ ដែលពាក់ព័ន្ធទៅនឹងការរៀបចំប្រព័ន្ធតុលាការ សមត្ថកិច្ចតុលាការ នីតិវិធីព្រហ្មទណ្ឌ ផ្លូវនៃបណ្តឹង ផ្លូវតវ៉ា ការអនុវត្តទោស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃទោស។

### ❖ ប្រតិសកម្មនៃច្បាប់សារធាតុ

ប្រតិសកម្មនៃច្បាប់សារធាតុ គឺស្រាលជាងគោលការណ៍មិនប្រតិសកម្មពោល គឺអនុវត្តតែក្នុងករណីដែលច្បាប់ថ្មីផ្តន្ទាទោសធ្ងន់ជាងច្បាប់ចាស់។

- កែប្រែបទល្មើសពីបទឧក្រិដ្ឋទៅបទមជ្ឈិម ឬពីបទមជ្ឈិមទៅបទលហុជាដើម។
- បន្ថយថិរវេលានៃការដាក់ទណ្ឌកម្ម ឬជំនួសទោសគុកដោយទោសពិន័យ ឬបន្ថយ ឬលុបចោលទោសគុកទោសពិន័យ ឬទោសបន្ថែមដែលមានក្រោមអំណាចច្បាប់ចាស់។
- លុបចោលបទល្មើសដែលកំណត់ដោយច្បាប់ចាស់។
- បន្ថែមធាតុផ្សំនៃបទល្មើស។ ការអនុវត្តភ្លាមនេះ (បទប្បញ្ញត្តិដែលចែងអំពីទោស ដែលស្រាលជាងត្រូវអនុវត្តភ្លាម) អាចធ្វើទៅបានតែក្នុងករណីដែលៈ
  - សំណុំរឿងនៃបទល្មើសត្រូវបានប្រព្រឹត្តមុនពេលច្បាប់ថ្មីចូលជាធរមាន។
  - ពុំទាន់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រម ឬសាលដីកាស្ថាពរនៅឡើយ។ និយាយម្យ៉ាងការផ្តន្ទាទោសដែលជាស្ថាពរហើយនោះត្រូវអនុវត្ត ទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មី ដែលចែងអំពី ទោសធ្ងន់ជាងនឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។[15] ក៏ប៉ុន្តែបទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះ គឺត្រូវអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន គឺមិនអាចត្រូវចោទប្រកាន់ទៀតឡើយ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ គឺត្រូវបញ្ចប់។ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ គឺមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។[16]

### ❖ ប្រតិសកម្មនៃច្បាប់សារធាតុ តាមការបញ្ញត្តិរបស់ច្បាប់

ក្នុងករណីមួយចំនួន ច្បាប់បានកំណត់អំពីអានុភាពប្រតិសកម្មនេះតែម្តង។ នេះជាករណីពិសេសដែលកើតមានក្នុងកាលៈទេសៈពិសេស ហើយករណីដូចនេះគឺកម្រនឹងកើតមានណាស់ព្រោះវាប៉ះពាល់ដល់សេរីភាពពលរដ្ឋ។ ប្រការ១១ នៃក្រឹត្យច្បាប់លេខ០២ ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៩៨០ ចែងថា អំពើប្រព្រឹត្តបទល្មើសទាំងឡាយដែលកើតមានក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រហូតដល់ថ្ងៃប្រកាសក្រឹត្យច្បាប់នេះ ហើយមិនទាន់បានជំនុំជម្រះ គឺត្រូវចោទប្ដឹងទៅតុលាការ និងជំនុំជម្រះតាមក្រឹត្យនេះ។ ប្រការ១២ នៃក្រឹត្យច្បាប់លេខ០៤ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៨១ ចែង

[15] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១០។

[16] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៩។

ថា ក្រឹត្យច្បាប់នេះ ត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយណាដែលបានកើតឡើងតាំងពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយដែលពុំទាន់ដាក់ជំនុំជម្រះនៅឡើយ។ អានុភាពប្រតិសកម្មនេះ ត្រូវកំណត់អំឡុងពេលច្បាស់លាស់។

❖ **ប្រតិសកម្មនៃច្បាប់សារធាតុក្នុងករណីផ្សេងទៀត**

មានន័យថា ដូចជាបទប្បញ្ញត្តិថ្មី ធ្វើការបកស្រាយបទប្បញ្ញត្តិចាស់ដោយបទបញ្ញត្តិចាស់មានខ្លឹមសារមិនច្បាស់លាស់។ ក្នុងករណីនេះ គឺកម្រនឹងកើតមានណាស់។

❖ **ការអនុវត្តភ្លាមៗនៃច្បាប់នីតិវិធី**

នៅពេលដែលមានច្បាប់នីតិវិធីចូលជាធរមាន ដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តី ឬដំណើរការរឿងព្រហ្មទណ្ឌជាដើម។ ច្បាប់ប្រភេទនេះ គឺត្រូវមានអានុភាពអនុវត្តភ្លាម ចំពោះគ្រប់អំពើដែលកើតមុន ហើយមិនទាន់ត្រូវបានជំនុំជម្រះតាមអំណាចសេចក្តីសម្រេចស្ថាពរនៅឡើយ ដែលគិតចាប់ពីថ្ងៃចូលជាធរមាន។ ប្រការដែលអនុវត្តបែបនេះ គឺច្បាប់ប្រភេទនេះ ពុំបានធ្វើឲ្យប៉ះពាល់ដល់អត្ថិភាពនៃបទល្មើសនោះទេ ហើយជាទូទៅច្បាប់ប្រភេទនេះ គឺគ្រាន់តែមានបំណងស្វែងរកជនល្មើស និងស្វែងរកការពិតឲ្យបានឆាប់រហ័ស និងកាន់តែមានប្រសិទ្ធិភាពតែប៉ុណ្ណោះ។ ហេតុនេះហើយ ទើបវាមិនបានធ្វើឲ្យប៉ះពាល់ដល់សុពលភាព នៃកិច្ចនីតិវិធីដែលធ្វើឡើងស្របតាមអំណាចច្បាប់ចាស់នោះទេ។ ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិ គឺគ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញសមស្របទៅតាមបទប្បញ្ញត្តិចាស់ឡើយ។[17]

### គ.ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងដែនដី

➢ **គោលការណ៍ដែនដីនៃច្បាប់ព្រហ្មទណ្ឌ** គឺក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្ត នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[18] បទល្មើស ត្រូវបានចាត់ទុកថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[19] គោលការណ៍ដែនដីនៃច្បាប់ព្រហ្មទណ្ឌ គឺរួមមានគោលការណ៍សំខាន់ៗដូចជា៖

[17] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១១។
[18] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១២។
[19] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៣។

- **គោលការណ៍ប្រព័ន្ធដែនដី**
  - អំពើទាំងឡាយណាដែលបានចាប់ផ្តើមប្រព្រឹត្តនៅលើដែនដីនៃប្រទេសកម្ពុជា ហើយបានបញ្ចប់សកម្មភាពល្មើសទាំងនោះ នៅលើដែនដីព្រះរាជាណាចក្រកម្ពុជា[20] ។
  - អំពើទាំងឡាយណាដែលបានចាប់ផ្តើមប្រព្រឹត្ត នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបានបញ្ចប់នៅឯបរទេស (សកម្មភាពល្មើស)។
  - អំពើទាំងឡាយណាដែលចាប់ផ្តើមប្រព្រឹត្តនៅឯបរទេស ហើយបានបញ្ចប់សកម្មភាពល្មើសទាំងនោះនៅលើដែនដីព្រះរាជាណាចក្រកម្ពុជា។
  - គោលការណ៍ដែលត្រូវផ្តន្ទាទោស គឺតម្រូវឲ្យមានការផ្តន្ទាទោសពីលើគ្រប់ជនល្មើសទាំងអស់ បើទោះបីជននោះជាពលរដ្ឋកម្ពុជាក្តី ឬជាជនបរទេសក្តី។ គេបានបែងចែកទៅតាមប្រភេទនៃជនល្មើសតាមប្រព័ន្ធដែនដី និងតាមលំដាប់ថ្នាក់ដូចតទៅៈ
    - ជនដែលគ្មានភារៈទទួលខុសត្រូវតាមប្រព័ន្ធដែនដីរួមមានដូចជាៈឯកអគ្គ រដ្ឋទូត, អគ្គរដ្ឋទូត, ប្រេសិត, ភារៈមេធាវី, ព្រមទាំងក្រុមគ្រួសារ, និងបុគ្គលិកស្ថានទូតក្នុងរយៈពេលដែលបំពេញបេសកម្មការទូត (ជនបរទេស ដែលបំរើការងារនៅស្ថានទូត)។ ជនបរទេសដែលបំរើការងារនៅស្ថានកុងស៊ុលបរទេសរួមមានដូចជាៈ អគ្គកុងស៊ុល, កុងស៊ុល, និងបុគ្គលិកកុងស៊ុល ហើយនិងព្រមទាំងក្រុមគ្រួសារ។ ជនបរទេសដទៃទៀតរួមមានដូចជាៈ តំណាងអង្គការសហប្រជាជាតិ, តំណាងរដ្ឋាភិបាល, និងតំណាងអង្គការក្រៅរដ្ឋាភិបាល ក្នុងដំណើរទស្សនៈកិច្ចក្រៅផ្លូវការក្តី ឬផ្លូវការក្តី។
    - ជនដែលមានភារៈទទួលខុសត្រូវតាមកិច្ចព្រមព្រៀងអន្តរជាតិ រួមមានដូចជាៈ ទាហាន, មន្ត្រីរាជការ, និយោជក, ភ្នាក់ងារបរទេស, និស្សិត, អ្នកធ្វើដំណើរឆ្លងកាត់, អ្នកតំណាងពាណិជ្ជកម្ម, ធានាគារ, និងអ្នកដំណើរកងនាវិក ឬយានិក។
    - ជនដែលមានភារៈទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌកម្ពុជា រួមមានដូចជាៈ ជនបរទេសដែលចូលមកប្រទេសកម្ពុជាដោយត្រឹមត្រូវតាមច្បាប់, ជនបរទេស

[20] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៣។

ο ដែលជាអ្នកវិនិយោគឯកជន និងអនិកជន ឬជនគ្មានសញ្ជាតិដែលនៅជាអចិន្ត្រៃ-យ៍លើដែនដីព្រះរាជាណាចក្រកម្ពុជា។

- **បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា** គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ បើទោះបីជានាវានោះស្ថិតនៅទីណា ក៏ដោយ[21]។ ច្បាប់កម្ពុជា គឺត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេស ដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឲ្យពិនិត្យមើល ឬឲ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។[22]
- **បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា** គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្ត នៅក្នុងអាកាសយានដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ។ [23] ច្បាប់កម្ពុជាក៏ត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូប ដែលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរត្រូវបានបំពេញដូចជា: បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេស និងអត្ថិភាពនៃបទល្មើស ដែលត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស។
- **សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក** គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាហើយបទល្មើសនោះជា[24] ៖
  - បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា។
  - បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា។
  - បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។
  - បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា
  - បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្ត ដោយពលរដ្ឋខ្មែរនៅក្រៅដែនដី

[21] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៤។
[22] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៥។
[23] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦។
[24] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២២។

នៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់កម្ពុជា ត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះ បើទោះបីជាជនជាប់ចោទនោះ បានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ។[25]

ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេស ទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរនៅក្នុងពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត។[26]

**២.១.៤ ការត្រួតពិនិត្យមើលនីត្យានុកូលភាពនៃច្បាប់ព្រហ្មទណ្ឌ**

អត្ថបទដែលបង្កើតបទល្មើសព្រហ្មទណ្ឌ គឺត្រូវតែស្របនឹងឋានានុក្រមថ្នាក់លើ បើពុំដូច្នោះទេ វានឹងត្រូវប្រកាសមោឃភាព មានន័យថាមិនត្រូវយកមកអនុវត្តទេ។

**២.២ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ**

**ធាតុសត្យានុម័ត** អាចហៅម៉្យាងទៀតថាធាតុផ្សំសម្ភារៈ គឺជាការប្រព្រឹត្តអំពើល្មើសនឹងច្បាប់ និងមានផលវិបាក ឬលទ្ធផលដែលកើតឡើងពី អំពើល្មើសនោះពិតប្រាកដ។ មានន័យថា សកម្មភាព ឬកាយវិការរបស់ជនល្មើសដែលស្តែងឡើងក្រោមរូបភាពសកម្មក្តី ឬអកម្មក្តី ហើយដើម្បីប្រព្រឹត្តអំពើល្មើស ជនល្មើសអាចប្រើប្រាស់មធ្យោបាយមួយចំនួនដូចជា: ការប្រើប្រាស់ឧបករណ៍ផ្សេងៗ ឬប្រើកលល្បិចបោកបញ្ឆោត ឬធ្វើសកម្មភាពពួនស្ទាក់ជាដើម។ **ឧទាហរណ៍:** ជនល្មើសប្រើកាំបិតចាក់ទៅលើជនរងគ្រោះ ដូច្នេះ ស្នាមនៅលើជនរងគ្រោះនោះ គឺត្រូវតែជាស្នាមកាំបិត មិនមែនស្នាមពូថៅ ឬគ្រាប់កាំភ្លើងនោះទេ។ ចំពោះធាតុសត្យានុម័តនេះរួមមានបទល្មើសដូចជា: បទល្មើសបានសម្រេច និងបទល្មើសមិនបានសម្រេច។

**២.២.១ បទល្មើសបានសម្រេច**

ជាបទល្មើសដែលជនល្មើសបានប្រព្រឹត្តបទល្មើសបានសម្រេចដូចបំណងរបស់ខ្លួន។ ជាក់ស្តែង ជនដែលប្រព្រឹត្តបទល្មើសនឹងត្រូវជាប់ពន្ធនាគារ ហើយជនរងគ្រោះ គឺអាចនឹងប៉ះពាល់ដល់ជីវិត បូរណភាពរូបកាយ និងប៉ះពាល់ដល់ទ្រព្យសម្បត្តិ រួមទាំងកម្មវត្ថុនៃបទល្មើសអាចប៉ះពាល់ដល់ជាតិថែមទៀតផង។ ក្នុងករណីនេះ គឺយើងសង្កេតឃើញថាបទល្មើសមានពីរសណ្ឋាន គឺបទល្មើសសកម្ម និងបទល្មើសអកម្ម ។

**ក.បទល្មើសសកម្ម**

គឺជាសកម្មភាពប្រព្រឹត្តយ៉ាងខិតខំរបស់ជនល្មើសដែលបង្កផលប៉ះពាល់ដល់សង្គម។ ជាក់

[25] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៩។

[26] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០។

ស្តែងបទល្មើសប្រភេទនេះ បានកើតមានឡើងជារឿយៗនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា អំពើលួចទ្រព្យសម្បត្តិអ្នកដ៏ទៃ អំពើមនុស្សឃាតដោយចេតនា និងអំពើបំពារបំពានលើរូបរាងកាយជាដើម។ បទល្មើសសកម្មស្តែងចេញឡើងតាមរូបភាពពីរយ៉ាងគឺ អំពើជាសម្ភារៈដែលជនល្មើសបានប្រព្រឹត្ត និងលទ្ធផលដែលបានកើតឡើងដោយសារអំពើនោះផ្ទាល់។

ថេរវេលានៃបទល្មើសសកម្ម គឺអាចជាអំពើប្រព្រឹត្តដែលកើតឡើងតែមួយភ្លែត ក្នុងរយៈពេលខ្លី ហើយសាមញ្ញាផងដែរ។ ឧទាហរណ៍: អំពើឃាតកម្ម គឺជនដៃដល់បានធ្វើសកម្មភាពដោយប្រើកាំភ្លើងបាញ់ប្រហារទៅជនរងគ្រោះចំនួន ៣គ្រាប់ ហើយអំពើរបស់ជនល្មើសបានបណ្តាលឲ្យជនរងគ្រោះស្លាប់ភ្លាមៗនៅនឹងកន្លែងតែម្តង ដោយសារតែការបាញ់ប្រហារពីជនល្មើស។

ហេតុនេះហើយបទល្មើស ដែលបានកើតឡើងដោយអំពើសកម្មចែកជាពីរប្រភេទ គឺបទល្មើសសម្ភារៈ និងបទល្មើសរូបភាព។

**ក.១ បទល្មើសសម្ភារៈ**

បទល្មើសសម្ភារៈ គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្ត ដោយបានប្រើប្រាស់នូវសម្ភារៈក្នុងការប្រព្រឹត្តបទល្មើស ដែលមានចរិតគ្រោះថ្នាក់ដល់សង្គម ដែលលទ្ធផលនៃបទល្មើសនោះបានបង្ហាញនូវធាតុផ្សំសត្យានុម័ត។

**ឧទាហរណ៍:**

- ជនល្មើសបានលើកដំបងវាយសំពងទៅលើជនរងគ្រោះ។
- ជនល្មើសបានលើកកាំភ្លើងបាញ់ជនរងគ្រោះ។

**ក.២ បទល្មើសរូបភាព**

បទល្មើសរូបភាពមានលក្ខណផ្ទុយពីបទល្មើសសម្ភារៈ។ **បទល្មើសរូបភាព** គឺជាបទល្មើសដែលគេមិនសំដៅទៅលទ្ធផលទៅជាយ៉ាងណានោះទេ គឺអោយតែសកម្មភាពបានប្រព្រឹត្តគេចាប់ទុកថាបទល្មើសបានសម្រេចហើយ។ បទល្មើសរូបភាពស្ថិតនៅលើការចោទប្រកាន់ទៅលើសកម្មភាពប្រព្រឹត្តតែម្តង។

**ឧទាហរណ៍៖**

- ការចូលរួមក្នុងក្រុមណាមួយដែលបង្កើតឡើង ឬចូលរួមក្នុងសន្និដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រឹដ្ឋប្រល័យពូជសាសន៍។[27]
- ឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋប្រល័យពូជសាសន៍។[28]

[27] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៨៥។

[28] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៨៥។

- ការរៀបចំចាត់តាំងក្រុមជនប្រដាប់អាវុធ។[29]

**ខ.បទល្មើសអកម្ម**

គឺជាអំពើដែលជនម្នាក់ មិនបានធ្វើទៅតាមការកំណត់ជាកាតព្វកិច្ចដែលច្បាប់តម្រូវអោយធ្វើ។ អំពើនេះ គឺទាល់តែច្បាប់មានចែងជាក់លាក់ថា ជាកាតព្វកិច្ចណាខ្លះដែលបុគ្គលគ្រប់រូបក្នុងសង្គម ឬបុគ្គលណាខ្លះត្រូវបំពេញ ហើយបើមិនបានបំពេញតាមច្បាប់កំណត់ទេនោះ គឺត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

**ឧទាហរណ៍៖**

- ការបដិសេធមិនចូលខ្លួនធ្វើជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬមុខតុលាការព្រហ្មទណ្ឌ[30]។
- ការបោះបង់អនីតិជន[31]។

**២.២.២ បទល្មើសមិនបានសម្រេច**

ជាទូទៅមុននឹងបានប្រព្រឹត្តបទល្មើសមួយ ដែលសម្រេចបានចេញជាផល ដែលចារីតែងតែសម្ដែងពីការប៉ុនប៉ងប្រព្រឹត្តបទល្មើសនោះរបស់ខ្លួនជាមុនសិន ហើយការប៉ុនប៉ងនៃការប្រព្រឹត្តបទល្មើសនេះ ទោះមិនបានសម្រេចជាផលក៏ដោយ ក៏ក្រមព្រហ្មទណ្ឌបានដាក់ទណ្ឌកម្មដល់ចារីដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសស្មើនឹងការប្រព្រឹត្តបទល្មើសសម្រេចជាផលដែរ។ ការប៉ុនប៉ងប្រព្រឹត្តបទល្មើស គឺសំដៅលើអំពើផ្ដួចផ្ដើមឡើងដើម្បីប្រព្រឹត្តបទល្មើសណាមួយ ដែលសកម្មភាពទាំងអស់នោះត្រូវតែមានលេចហេតុឲ្យឃើញថា បានចាប់ផ្ដើមអនុវត្តគំនិតហើយ ប៉ុន្តែមិនទាន់បានសម្រេចក៏ខកខានទៅវិញ ដោយសារតែកាលៈទេសៈ ឬមានអំពើអ្វីមួយមកបង្អាំង ដែលក្រៅពីឆន្ទៈរបស់អ្នកប្រព្រឹត្ត។ **ឧទាហរណ៍:** បុគ្គលម្នាក់បានចាប់ផ្ដើមបាញ់កាំភ្លើងទៅកាន់រូបវន្តបុគ្គលម្នាក់ ៣ទៅ៤គ្រាប់ ប៉ុន្តែមិនត្រូវសោះ ខណៈពេលនោះប៉ូលីសបានមកដល់ភ្លាម ហើយបានចាប់បុគ្គលដែលបានប្រើប្រាស់កាំភ្លើងនោះទៅស្នងការនគរបាលតែម្ដង។ អំពើដែលបានលេចហេតុឲ្យឃើញនេះហើយទើបអាចចាត់ទុកថាជាការប៉ុនប៉ងប្រព្រឹត្តបទល្មើសឃាតកម្មបាន។

**ក.លក្ខខណ្ឌនៃអំពើប៉ុនប៉ងត្រូវមានទោស**

អំពើប៉ុនប៉ង អាចនឹងត្រូវបានផ្ដន្ទាទោសចំពោះជន ដែលប្រព្រឹត្តអំពើនេះបានលុះត្រាតែគោរពតាមលក្ខខណ្ឌពីរគឺ[32]៖

[29] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៨៦។

[30] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥៣៨។

[31] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២១។

[32] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៧។

- ចារីបានចាប់ផ្ដើមប្រព្រឹត្តបទល្មើស មានន័យថាចារីបានប្រព្រឹត្ត អំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តទេ តែត្រូវបានរាំងស្ទះ ឬអាក់ខានដោយសារឥទ្ធិពលនៃកាលៈទេសៈ ខាងក្រៅឆន្ទៈរបស់ចារី។

**ខ.ការដាក់ទណ្ឌកម្មលើការប៉ុនប៉ង**

នៅក្នុងក្រមព្រហ្មទណ្ឌ បានកំណត់នូវបញ្ញត្តិមួយចំនួនដែល តម្រូវអោយជនល្មើសទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនទៅ តាមបទល្មើសដែលខ្លួនបានប្រព្រឹត្ត ។ ប៉ុន្តែក៏មានបទល្មើសខ្លះក្រមព្រហ្មទណ្ឌមិនបានដាក់ទណ្ឌកម្ម ចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើសនោះទេ។ ជាទូទៅចៅក្រមក៏មិនដាក់ទោសទៅលើចារី អោយធ្ងន់ធ្ងរដូចជាចារីប្រព្រឹត្តបទល្មើសបានសម្រេចនោះឡើយ។

**ខ.១ ចំពោះបទឧក្រិដ្ឋ**

ចំពោះការប៉ុនប៉ងលើបទឧក្រិដ្ឋគ្រប់ប្រភេទ គឺត្រូវតែមានទោស ឬត្រូវតែផ្តន្ទាទោស។[33] គ្មានការប្រព្រឹត្តបទល្មើសឧក្រិដ្ឋណាមួយដែលមិនកើតចេញពីការប៉ុនប៉ងនោះទេ។

**ខ.២ ចំពោះបទមជ្ឈិម**

ការប៉ុនប៉ងក្នុងបទមជ្ឈិមអាចផ្តន្ទាទោសបាន លុះត្រាតែមានច្បាប់ចែងដាក់លាក់។[34] ដើម្បីអាចផ្តន្ទាទោសលើការប៉ុនប៉ងក្នុងបទល្មើសមជ្ឈិមណាមួយបាន លុះត្រាតែមានច្បាប់ចែងយ៉ាងច្បាស់លាស់ថា ការប៉ុនប៉ងក្នុងបទមជ្ឈិមណាមួយត្រូវមានទោស ឬត្រូវផ្តន្ទាទោសតាមទម្ងន់នៃបទល្មើសនោះ។

**ខ.៣ ចំពោះបទលហុ**

ការប៉ុនប៉ងនៅក្នុងបទលហុ គឺពុំត្រូវទទួលការផ្តន្ទាទោសទេ។[35] បើសិនជាបុគ្គលណាមួយបានប្រព្រឹត្តបទលហុ បុគ្គលនោះពុំត្រូវផ្តន្ទាទោស ឬទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទៅការប៉ុនប៉ងទេ ដោយសារច្បាប់ មិនបានចែងអោយមានការផ្តន្ទាទោសលើការប៉ុនប៉ងក្នុងបទលហុឡើយ។

**គ. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស**

ជាគោលការណ៍ដំណាក់កាលនៃការប្រព្រឹត្តបទល្មើសបានបែងចែកជា ៩ គឺៈ

– ដំណាក់កាលទី១ គឺជាដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស។

---

[33] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៧។

[34] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៧។

[35] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៧។

– ដំណាក់កាលទី២ គឺជាដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស។

– ដំណាក់កាលទី៣ គឺជាដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស។

– ដំណាក់កាលទី៤ គឺជាដំណាក់កាលនៃការសម្រេចបទល្មើស ឬបទល្មើសប៉ុនប៉ង។

ជារួមមកដំណាក់កាលទាំងបួនខាងលើនេះ ច្បាប់មិនបានផ្តន្ទាទោសគ្រប់ដំណាក់កាលទាំងអស់នោះទេ គឺលុះត្រាតែសកម្មភាពនោះបានស្តែងចេញមកខាងក្រៅ។ ដូច្នេះ ដើម្បីដឹងថាដំណាក់កាលណាខ្លះដែលច្បាប់មានចែងឲ្យមានការផ្តន្ទាទោស ហើយនិងដំណាក់កាលណាខ្លះទៀតដែលច្បាប់ពុំបានចែងឲ្យមានការផ្តន្ទាទោសនោះ គឺរួមមានដំណាក់កាលដូចតទៅ។

### គ.១ ដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស

ដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស គឺជាដំណាក់កាលដំបូងដែលជនល្មើសគ្រាន់តែគិតនៅក្នុងចិត្ត ប៉ុន្តែពុំទាន់បានធ្វើសកម្មភាពនៅឡើយទេ។ ក្រោយពីការគិត ការធ្វើសកម្មភាព ឬការមិនធ្វើសកម្មភាព វាជាការសម្រេចចិត្តរបស់ជនល្មើស។ ប៉ុន្តែអ្វីដែលចង់បញ្ជាក់នៅក្នុងដំណាក់កាលនេះ គឺច្បាប់ពុំទាន់បានចែងឲ្យផ្តន្ទាទោស ចំពោះអ្នកដែលគិតនឹងសម្រេចប្រព្រឹត្តបទល្មើសណាមួយ ដោយហេតុថា បទល្មើសមួយនោះពុំទាន់លិចជារូបរាងមកខាងក្រៅ ហើយនិងមិនរងព្យសនកម្មដល់សង្គម។ ឧទាហរណ៍: បុរសម្នាក់ឈ្មោះ(ក) មានទំនាក់ស្នេហាជាមួយនារីម្នាក់ឈ្មោះ(ខ)។ ដោយថ្ងៃមួយមានបុរសម្នាក់ឈ្មោះ(គ) បានមកចែចង់ផ្គោះផ្គងស្នេហាជាមួយនារីឈ្មោះ(ខ) ហើយពេលនោះបុរសឈ្មោះ(ក) បានមកឃើញបុរសឈ្មោះ(គ) កំពុងតែចែចង់ផ្គោះផ្គងស្នេហាជាមួយនារីឈ្មោះ(ខ) ពេលនោះបុរសឈ្មោះ(ក) ក៏កើតជាកំហឹងគុំគួនទៅលើបុរសឈ្មោះ(គ)នោះ។ ក្នុងករណីនេះមានន័យថា នៅក្នុងដំណាក់កាលនៃការគិត និងការសម្រេចចិត្ត របស់បុរសឈ្មោះ(ក) គឺមិនត្រូវទទួលការផ្តន្ទាទោសនោះឡើយ ដោយហេតុថាគ្រាន់តែជាការគិត និងការសម្រេចចិត្តរបស់បុរសឈ្មោះ(ក) គឺមិនអាចបង្កព្យសនកម្ម ឬបង្កផលប៉ះពាល់ដល់បុរសឈ្មោះ(គ) នោះឡើយ។

### គ.២ ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស

ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស គឺជាដំណាក់កាល ជនដែលបម្រុង និងប្រព្រឹត្តបទល្មើសដែលពួកគេបានត្រៀមជាឧបករណ៍ ដែលសម្រួលឲ្យការប្រព្រឹត្តបទល្មើសមានប្រសិទ្ធិភាព។ មានន័យថា បើទោះបីជាជននោះបានធ្វើការសម្រេចចិត្ត និងការរៀបចំជាឧបករណ៍ដែលសម្រួលឲ្យ បទល្មើសនោះ មានប្រសិទ្ធិភាពក៏ដោយ ក៏ការគិត និងការរៀបចំឧបករណ៍នោះ គឺពុំអាចបង្កឲ្យមានព្យសនកម្ម ឬផលប៉ះពាល់ដល់សង្គម ឬជនណាម្នាក់បានឡើយ។ ឧទាហរណ៍: បុរសឈ្មោះ(ក) មានទំនាស់ជាមួយបុរសឈ្មោះ(ខ)។ ស្រាប់តែនៅថ្ងៃមួយបុរសឈ្មោះ(ក) បាន

ត្រៀមរៀបចំឧបករណ៍ ដោយយកដំបង ដើម្បីទុកវាយទៅលើបុរសឈ្មោះ(ខ)។ ក្នុងករណីនេះ មានន័យថា នៅក្នុងដំណាក់កាលនៃការត្រៀមរៀបចំរបស់បុរសឈ្មោះ(ក)នោះ គឺមិនត្រូវទទួលការផ្តន្ទាទោសនោះឡើយ ដោយហេតុថាគ្រាន់តែជាការត្រៀមរៀបចំរបស់បុរសឈ្មោះ(ក) គឺមិនអាចបង្កព្យសនកម្ម ឬបង្កផលប៉ះពាល់ដល់បុរសឈ្មោះ(ខ) នោះឡើយ។

**គ.៣ ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស**

ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស គឺជាដំណាក់កាលដែលជននោះបានចាប់ផ្តើមប្រព្រឹត្តបទល្មើសតាមការគិត និងសម្រេចចិត្ត ហើយនិងការត្រៀមរៀបចំប្រព្រឹត្តបទល្មើសនោះ។ ឧទាហរណ៍: បុរសឈ្មោះ(ក) បានយកដំបងមកវាយបុរសឈ្មោះ(ខ)។ ក្នុងករណីនេះ មានន័យថាអំពើរបស់បុរសឈ្មោះ(ក)នោះ គឺបានចាប់ផ្តើមសកម្មភាពប្រព្រឹត្តបទល្មើសទៅលើបុរសឈ្មោះ(ខ)។

**គ.៤ ដំណាក់កាលនៃការសម្រេចបទល្មើស ឬបទល្មើសប៉ុនប៉ង**

ដំណាក់កាលនៃការសម្រេចបទល្មើស ឬបទល្មើសប៉ុនប៉ង គឺជាដំណាក់ចុងក្រោយបំផុតនៃការប្រព្រឹត្តបទល្មើស។ ក្នុងដំណាក់កាលនេះ គឺជនល្មើសអាចទទួលបាននូវលទ្ធផលពីរយ៉ាងគឺៈ

- ទី១ ប្រសិនបើលទ្ធផលនៃការប្រព្រឹត្តបទល្មើស បានបំពេញតាមបំណងរបស់ជនល្មើសនោះ គឺមានន័យថាបទល្មើសនោះ គឺជាបទល្មើសបានសម្រេច។
- ទី២ ផ្ទុយទៅវិញប្រសិនបើលទ្ធផលនៃការប្រព្រឹត្តបទល្មើសនោះ មិនស្របតាមបំណង ឬឆន្ទៈរបស់ជនល្មើសនោះ ដោយគ្រាន់តែផ្តល់នូវព្យសនកម្មធ្ងន់ធ្ងរ ឬស្រាលដល់ជនរងគ្រោះនោះ គឺហៅថាជាបទល្មើសប៉ុនប៉ង។

## ២.៣ ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ

គឺជាចិត្តគំនិតខាងក្នុងរបស់ជនល្មើស ដែលវាស្តែងមកខាងក្រៅតាមរយៈធាតុសត្យានុម័ត ដូចជា: កាយវិការ ឬអំពើប្រព្រឹត្តរបស់ជនល្មើស។ ធាតុអន្តោម័តស្តែងឡើងក្រោមរូបភាពដូចជា: កំហុស, មូលហេតុ និងកត្តាផ្សេងៗ ដែលជំរុញឲ្យប្រព្រឹត្តបទល្មើស។

### ២.៣.១ អំពីកំហុស

កំហុស គឺជាកិរិយាមាយាទរបស់ជនល្មើស ដែលបានស្តែងឡើងក្រោមរូបភាពជាចេតនា ឬអចេតនាក្នុងការប្រព្រឹត្តបទល្មើស។

អំពើរបស់មនុស្សម្នាក់អាចចាត់ទុកថាជាអំពើដែលមានកំហុសបាន គឺលុះត្រាតែបានប្រព្រឹត្តអំពើប្រកបដោយចារឹកគ្រោះថ្នាក់ដល់សង្គម មានន័យថាការប្រព្រឹត្តអំពើ គឺជាលទ្ធផលនៃការសម្រេច និងជ្រើសរើសដោយខ្លួនឯង គឺក្នុងខណៈនោះខ្លួនមានលទ្ធភាពគ្រប់គ្រាន់នឹងធ្វើការជ្រើស

រើស និងសម្រេចនូវសកម្មភាពផ្សេងៗទៀត ដែលសមស្របទៅនឹងសំណូមពររបស់សង្គម តែខ្លួនបែរជាជ្រើសរើសយកនូវការប្រព្រឹត្តអំពើល្មើសបែបនេះទៅវិញ។

**ក.កំហុសដោយចេតនា**

ចេតនាប្រព្រឹត្តបទល្មើស ជាចេតនាដែលជនល្មើសបានយល់ដឹងពីស្ថានភាព នៃអំពើរបស់ខ្លួន ដែលអាចកំរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួន និងបានដឹងមុនចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។ **ឧទាហរណ៍៖** ឈ្មោះ "**ក**" បានយកដំបងប្រវែង១ម៉ែត្រ ទៅវាយចំក្បាលឈ្មោះ "**ខ**" បណ្តាលអោយដួលបែកក្បាល ហើយក្រោយមក ខ ក៍បានស្លាប់បាត់បង់ជីវិត។

**ខ.កំហុសដោយអចេតនា**

អចេតនាប្រព្រឹត្តបទល្មើស ជាការប្រព្រឹត្តបទល្មើសដែលបានដឹងជាមុនថា អំពើរបស់ខ្លួនអាចបង្កអោយមានគ្រោះថ្នាក់ដល់សង្គម ដែលកើតដោយសារការ ធ្វេសប្រហែស ឬការខ្ជីខ្ជារ។ **ឧទាហរណ៍៖** ឈ្មោះ "**ក**" បានកាប់ដើមឈើដ៏ធំដែលនៅមុនផ្ទះរបស់ខ្លួន ហើយបានបាក់ សង្កត់លើឈ្មោះ "**ខ**" ដែលបានធ្វើដំណើរកាត់តាមផ្លូវនោះ បណ្តាលអោយស្លាប់បាត់បង់ជីវិត។

**២.៣.២ មូលហេតុ ឬគំនិតផ្តួចផ្តើមបទល្មើស**

ចិត្តជាធម្មជាតិមួយសន្សំនូវចេតនា។ នៅពេលដែលមានឥទ្ធិពលពីខាងក្រៅមកប៉ះនឹងផ្ទៃចិត្តញយៗដងវានឹងជំរុញអោយអោយមនុស្សធ្វើសកម្មភាពអ្វីមួយឆ្លើយតបទៅនឹងអំពើនោះ។ ដូចនេះការឆ្លើយតបទៅនឹងអំពើល្មើស គឺជាកត្តាផ្លូវចិត្តខាងក្នុងដែលជំរុញឲ្យមនុស្សប្រព្រឹត្តបទល្មើស។ គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស កើតមានឡើងដោយសារ តម្រូវការរបស់មនុស្សខាងសម្ភារៈស្មារតី និងបញ្ហាផលប្រយោជន៍ ប៉ុន្តែបុគ្គលនោះ ជ្រើសរើសយកនូវឥរិយាបថ និងប្រព្រឹត្តនូវសកម្មភាពប្រយោជន៍ និងសណ្តាប់ធ្នាប់សង្គម។

គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស មានតែករណីបទល្មើសដោយចេតនាប៉ុណ្ណោះ ចំណែកបទល្មើសដោយអចេតនា ជនល្មើសពុំមានបំណងប្រព្រឹត្តបទល្មើស មិនយល់ដឹងអំពើរបស់ខ្លួនដែលកើតឡើងពីការធ្វេសប្រហែស។ ដូច្នេះនៅក្នុងបទល្មើសអចេតនា ពេលធ្វើសកម្មភាព ផ្នែកផ្លូវចិត្តខាងក្នុង របស់ជនល្មើស ពុំមានគំនិតផ្តួចផ្តើមជំរុញអោយជននោះប្រព្រឹត្តឡើយ។

**២.៣.៣ គោលដៅនៃការប្រព្រឹត្តបទល្មើស**

គោលដៅនៃការប្រព្រឹត្តបទល្មើស ជាអ្វីដែលជនល្មើសមានបំណងចង់បានដោយឆ្លងកាត់ការប្រព្រឹត្តបទល្មើស។ នៅក្នុងគំនិតរបស់ជនល្មើសផ្ដុំឡើង យ៉ាងច្បាស់លាស់នូវសញ្ញាណមួយដែលជា គោលដៅរបស់ជនល្មើសដែលចង់បាន មានន័យថា គោលដៅនៃបទល្មើសមាននៅក្នុងគំនិត មាននៅក្នុងអារម្មណ៍របស់ជនល្មើស តាំងតែពីពេលដែលជននោះគិតថាប្រព្រឹត្តបទល្មើសមក

ម្ល៉េះ។ គោលដៅនៃការប្រព្រឹត្តបទល្មើសមានតែទៅលើបទល្មើសដោយចេតនាទេ ដែលជនល្មើសបានដឹងមុនចំពោះទង្វើរបស់ខ្លួន ហើយមានបំណងអោយប្រាថ្នាអោយអំពើនេះកើតឡើង។

ជាគោលការណ៍ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ឬការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។ មានន័យថា ធាតុអត្តនោម័ត គឺសំដៅទៅលើចិត្តគំនិតរបស់ជនល្មើសដែលបង្កដោយចេតនាក្តី ឬអចេតនាក្តី ក្នុងការប្រព្រឹត្តបទល្មើស។ ធាតុអត្តនោម័តខ្លះស្តែងឡើងដោយការគិតទុកជាមុន ហើយនិងខ្លះទៀតស្តែងឡើងភ្លាមៗរបស់ជនល្មើស ក្នុងការប្រព្រឹត្តបទល្មើសអ្វីមួយ។

# ជំពូកទី៣
# ចំណាត់ថ្នាក់នៃបទល្មើស

# ជំពូកទី៣៖ ចំណាត់ថ្នាក់នៃបទល្មើស

ដើម្បីស្គាល់ឲ្យបានច្បាស់នូវប្រភេទនៃបទល្មើសនីមួយៗ គឺជាការចាំបាច់ណាស់ដែលត្រូវតែធ្វើចំណាត់ថ្នាក់នៃបទល្មើសទាំងអស់ ក្នុងគោលដៅសម្រួលដល់ការកំណត់ និងស្គាល់នូវរបបគតិយុត្ត ក្នុងការអនុវត្តចំពោះបទល្មើសណាមួយ។ ការបែងចែកបទល្មើសដែលសំខាន់ជាងគេបំផុតគឺការបែងចែករវាង **បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ** ។

## ៣.១ ការបែងចែករវាងបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ

មាត្រា២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានបញ្ញត្តិថា **បទល្មើស** ត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។

ចំពោះការបែងចែកបទល្មើស គឺត្រូវបានបែងចែកជា**៣ប្រភេទ** ទៅតាមលក្ខណៈធ្ងន់ធ្ងរនៃបទល្មើស គឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងនីតិព្រហ្មទណ្ឌ ពីព្រោះថាការបែងចែកបទល្មើសនាំមកនូវផលប្រយោជន៍ទាក់ទងនឹងរបបគតិយុត្ត ដែលច្បាប់រមែងតែងតែភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើស។

### ៣.១.១ លក្ខណៈវិនិច្ឆ័យនៃការបែងចែក

ដើម្បីអាចដឹងពីប្រភេទនៃបទល្មើសបាន គឺគេត្រូវពិនិត្យទៅលើអតិប្បរមានៃទោស ដែលច្បាប់បានចែងនៅលើបទល្មើសនីមួយៗ។

#### ក.បទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិប្បរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងគឺ៖

- ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។
- ជាទោសដាក់ពន្ធនាគារដែលមានរយៈពេលលើសពី**៥ឆ្នាំ** និងក្រោម ឬស្មើនឹង**៣០ ឆ្នាំ**។

**ឧទាហរណ៍ ៖**

- បទឃាតកម្មគិតទុកជាមុន (មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ )។
- បទរំលោភសេពសន្ថវៈ (មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)។
- បទរួមភេទជាមួយអនីតិជនដោយបុព្វាតិ (មាត្រា៣៥១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ )។
- បទទារុណកម្ម និងអំពើឃោរឃៅ (មាត្រា២១០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ )។
- បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ (មាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ )។

**ខ.បទមជ្ឈិម**

**បទល្មើសជាមជ្ឈិម** គឺមាននៅក្នុងករណីដែល អតិប្បរមានៃទោសដាក់ពន្ធនាគារដែលត្រូវរង នោះមានរយៈពេលលើសពី **៦ថ្ងៃ** និងក្រោម ឬស្មើនឹង **៥ឆ្នាំ ( មាត្រា ៤៧ )**។

**ឧទាហរណ៍ ៖**

- បទមនុស្សឃាតដោយអចេតនា ( មាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩)។
- បទប្រទូស្តកេរខ្មាស ( មាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)។
- បទរុកកួនខាងផ្លូវភេទ ( មាត្រា២៥០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)។
- បទរំលោភលើលំនៅឋាន ( មាត្រា២៥៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩)។

**គ.បទលហុ**

**បទល្មើសជាបទលហុ** គឺមាននៅក្នុងករណីដែល៖

- អតិប្បរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះមានរយៈពេលក្រោម ឬស្មើនឹង ៦ ថ្ងៃ។
- បទល្មើស ត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

**ឧទាហរណ៍:** បើកបរដោយមិនពាក់ខ្សែក្រវ៉ាត់ការពារ ឬមិនពាក់មួកការពារសុវត្ថិភាព ឬបើកបរហួសល្បឿនកំណត់។

**៣.១.២ ផលប្រយោជន៍នៃការបែងចែក**

**ក.ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល**

**អាជ្ញាយុកាល** គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ដោយបុគ្គលម្នាក់អាចបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធិណាមួយជាប្រយោជន៍ដល់ខ្លួនឯង។ ក្នុងច្បាប់ព្រហ្មទណ្ឌ **អាជ្ញាយុកាលមាន២ប្រភេទ** គឺៈ (**១**) អាជ្ញាយុកាលនៃបទល្មើស ឬបណ្តឹងអាជ្ញា និង (**២**) អាជ្ញាយុកាលនៃទោស។

**១.អាជ្ញាយុកាលនៃបទល្មើស** គឺជារយៈពេលមួយកំណត់ដោយច្បាប់ ដែលផុតរយៈពេលនេះ គឺព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចធ្វើបណ្តឹងអាជ្ញាបានឡើយ។ អាជ្ញាយុកាលប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស។ ថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា[36] រួមមានដូចខាងក្រោម ៖

- ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ។
- ៥ ឆ្នាំ ចំពោះបទមជ្ឈិម។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១០។

- ១ ឆ្នាំ ចំពោះបទលហុ។

ជាគោលការណ៍អាជ្ញាយុកាលនៃបទល្មើស គឺចាប់ផ្តើមរាប់ពីពេលដែលប្រព្រឹត្តបទល្មើសទៅ។

**២.អាជ្ញាយុកាលនៃទោស** គឺជារយៈពេលមួយកំណត់ដោយច្បាប់ ដែលផុតរយៈពេលនេះ គឺទោសលែងអាចអនុវត្តបានទៀតហើយ។ រយៈពេលអាជ្ញាយុកាលនៃទោស[37] រួមមានដូចខាងក្រោម៖

- ទោសដែលប្រកាស ពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ ឆ្នាំ។
- ទោសដែលប្រកាស ពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ ឆ្នាំ។
- ទោសដែលប្រកាស ពីបទលហុមានអាជ្ញាយុកាល ១ ឆ្នាំ។

### ខ.ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី

នៅក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌ នីតិបញ្ញត្តិខ្មែរ គឺកំណត់នូវគោលការណ៍មួយចំនួនដោយផ្អែកលើប្រភេទនៃបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម។ **ឧទាហរណ៍:** ក្នុងករណីជាបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ដោយធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។[38] ប្រសិនបើរឿងនោះជាបទល្មើសជាក់ស្តែង ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការ ដើម្បីធ្វើការជំនុំជម្រះដោយផ្ទាល់។[39]

### គ.ផលប្រយោជន៍ទាក់ទងនឹងការកំណត់បទល្មើសប៉ុនប៉ង

មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម គឺអាចត្រូវផ្តន្ទាទោសបានកាលណាបើលក្ខខណ្ឌត្រូវបានបំពេញដូចខាងក្រោម៖

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស។
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។ អំពើត្រៀមបម្រុងដែល មានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ។ ការប៉ុនប៉ងក្នុងបទលហុពុំត្រូវទទួលការផ្តន្ទាទោសទេ។[40]

[37] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៥៥។
[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤។
[39] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៩។
[40] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៧។

**ឃ.ផលប្រយោជន៍ទាក់ទងនឹងការកំណត់ការផ្តើមគំនិត និងការសមគំនិត**

មាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលៈ

- ជម្រុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬការបញ្ជារ ។
- បង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់អំណោយដោយការសន្យា ឬការគម្រាមកំហែង ឬការញុះញង់ ឬការលួងលោម ឬ ការរំលោភបំពានពីអ្នកដែលមានអំណាចមកលើខ្លួន។ អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។ មួយវិញទៀតត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។[41]

## ៣.២ ការបែងចែករវាងបទល្មើសដោយចេតនា និងបទល្មើសអចេតនា

ជាគោលការណ៍ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។[42]

### ៣.២.១ បទល្មើសដោយចេតនា

ជាបទល្មើសដែលចារីមានបំណងប្រព្រឹត្ត។ **ឧទាហរណ៍:** ចោរមានចេតនាលួចយកទ្រព្យសម្បត្តិរបស់អ្នកដទៃ មានន័យថាបំណងយកទ្រព្យរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន គឺជាបំណងប្រព្រឹត្តបទល្មើស។

### ៣.២.២ បទល្មើសដោយអចេតនា

គឺជាបទល្មើសដោយអចេតនាដែលស្តែងឡើង ដោយភាពសុចរិតរបស់ចារីដែលពុំបានតាំងចិត្តថានឹងប្រព្រឹត្តបទល្មើសនោះទេ ពោលគឺបើទោះបីជាចារីពុំមានបំណងទុច្ចរិតក៏ដោយ ក៏នៅតែមានបទល្មើសកើតឡើងបានដដែល។

---

[41] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៩។

[42] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤។

**ឧទាហរណ៍:** មនុស្សឃាតដោយអចេតនា, បើកបរដោយបង្កឲ្យស្លាប់ដល់អ្នកដទៃដោយអចេតនា, បើកបរបង្កឲ្យមានរបួសដល់អ្នកដទៃដោយអចេតនា។ ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌ មិនត្រឹមតែដាក់ទោស ចំពោះការប្រព្រឹត្តបទល្មើសបានសម្រេចនោះទេ គឺថែមទាំងដាក់ទោសលើការប៉ុនប៉ងប្រព្រឹត្តបទល្មើសផងដែរ កាលបើលក្ខខណ្ឌនៃការប៉ុនប៉ងមានទោស ត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។

## ៣.៣ ការបែងចែករវាងបទល្មើសនយោបាយ បទល្មើសយោធា និងបទល្មើសភេរវកម្ម

### ៣.៣.១ បទល្មើសនយោបាយ

តាមការពិតទៅ គឺគ្មានបទល្មើសនយោបាយទេ គឺមានតែបទល្មើសមានចរិតជានយោបាយ។ បទល្មើសនយោបាយ គឺដូចឈ្មោះរបស់វាប្រាប់ស្រាប់ គឺមានន័យថាកម្មវត្ថុនៃបទល្មើសដែលទាក់ទងនឹងបញ្ហានយោបាយ ពោលគឺជាបទល្មើសដែលធ្វើឲ្យប៉ះពាល់ដល់ការរៀបចំ និងការប្រព្រឹត្តទៅជាប្រក្រតីនៃអំណាចសាធារណៈ។ និយាយឲ្យខ្លីទៅជាបទល្មើសដែលកើតឡើងដោយហេតុផលនយោបាយ។ ក្រមព្រហ្មទណ្ឌ គឺពុំបានចែងពីបទល្មើសនយោបាយទេ។

### ៣.៣.២ បទល្មើសយោធា

ក្រមព្រហ្មទណ្ឌ គឺពុំបានបញ្ជាក់ថាតើបទល្មើសដែលមានចែងក្នុងជំពូកទី២ មាតិកាទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ទោះបីជាប្រព្រឹត្តដោយយោធិនក៏ពុំអាចបង្កើតជាបទល្មើសយោធាដែរ។

**បទល្មើសយោធា** គឺជាបទល្មើសដែលទាក់ទងនឹងដល់យោធិនទាំងយោធិនជាប់កិច្ចសន្យាទាំងយោធិនកំណែន, ទាំងការពាក់ព័ន្ធដល់បទពិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា។[43] បទល្មើសយោធាស្ថិតនៅក្រោមសមត្ថកិច្ចតុលាការយោធា ហើយក្រៅពីបទពីន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា ( ជាទូទៅការបំពានច្បាប់ជាបទល្មើស តែបើពិនិត្យវិស័យនៃការបំពានវិញវាពិតជាមានឥទ្ធិពលលើការកំណត់ប្រភេទនៃបទល្មើស) ជាសមត្ថកិច្ចរបស់តុលាការនៃនីតិរូម។[44]

### ៣.៣.៣ បទល្មើសភេរវកម្ម

**អំពើភេរវកម្ម** គឺជាប្រភេទបទល្មើសថ្មីនាសតវត្សទី២១ នេះ ហើយក៏ជាប្រភេទនៃបទល្មើសដែលមតិភាគច្រើនបានយល់ស្របគ្នាថា ជាបទល្មើសដ៏សែនគ្រោះថ្នាក់បំផុត ចំពោះមនុស្សជាតិមិនត្រឹមតែសម្រាប់ជាតិណាមួយនោះទេ តែចំពោះសហគមន៍អន្តរជាតិទាំងមូល។ **អំពើភេរវកម្ម** គឺជាអំពើហិង្សាទាំងឡាយ ដែលប្រព្រឹត្តដោយជនមួយនាក់ ឬច្រើននាក់ ឬជនមួយក្រុមបានបង្កើតការភិតភ័យតក់ស្លុត ក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើឲ្យច្របល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់ និង

---

[43] ច្បាប់ស្តីពីព្រហ្មទណ្ឌអន្តរកាល, ១០ កញ្ញា ១៩៩២, មាត្រា១១។

[44] សាស្ត្រាចារ្យ សែ វ៉េង, នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ,២០១៣) ។

សន្តិសុខជាសាធារណៈ និងធ្វើឲ្យប៉ះពាល់ដល់ស្ថិរភាពនយោបាយ។ ច្បាប់នេះបានអនុវត្តលើអំពើភេរវកម្ម ការចាប់ជម្រិត និងបង្ខាំងមនុស្សដោយខុសច្បាប់ ក្នុងគោលដៅធ្វើវិច្ឆេទកម្ម ទារប្រាក់សងសងសឹក ធ្វើជាចំណាប់ឃ្នាំងយកទៅលក់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ១០ឆ្នាំ ទៅ២០ឆ្នាំ ឬអស់មួយជីវិត។ ក្នុងករណី (១)អនីតិភាពនៃជនរងគ្រោះ, (២) មរណៈភាពនៃជនរងគ្រោះ និង (៣) ការគិតទុកជាមុន។ ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ឆ្នាំ២០០៧ ត្រូវបានរៀបចំឡើងដើម្បីឲ្យកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទប់ស្កាត់អំពើភេរវកម្ម។ ជាពិសេសសក្តានុពលនៃអំពើភេរវកម្មអាចកើតឡើងនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ ច្បាប់នេះ កំណត់បទល្មើសទាំងឡាយណាដែលចាំបាច់ដែលចែងពីលទ្ធភាព និងការរឹបអូសទ្រព្យបម្រើឲ្យភេរវកម្មព្រមទាំងធ្វើ **បត្យាប័ន** និងការជួយគ្នាទៅវិញទៅមកជាអន្តរជាតិ។

### ៣.៤ ផលប្រយោជន៍នៃការបែងចែកបទល្មើស (ទាក់ទងនឹងសមត្ថកិច្ច)

- **សមត្ថកិច្ចតាមបទល្មើស** គឺជាសមត្ថកិច្ចមួយដែលគេកំណត់តាមប្រភេទបទល្មើស ។
- **សមត្ថកិច្ចតាមជនល្មើស** គឺជាសមត្ថកិច្ចមួយដែលគេជំនុំជម្រះ តាមប្រភេទអ្នកប្រព្រឹត្តបទល្មើស។
- **សមត្ថកិច្ចតាមដែនដី** គឺត្រូវបានបែងចែកជា៣ប្រភេទទៀតគឺ៖
  - ជួនកាលជាកន្លែងបទល្មើសកើតឡើង មានន័យថាបទល្មើសកើតឡើងនៅទីណា គឺសមត្ថកិច្ចរបស់តុលាការនៅទីនោះ។
  - ជួនកាលជាទីកន្លែងស្នាក់នៅបណ្តោះអាសន្ន មានន័យថាជនល្មើសពួននៅទីណា គឺសមត្ថកិច្ចរបស់តុលាការនៅកន្លែងនោះ។
  - ជួនកាលកន្លែងដែលគេចាប់ខ្លួន មានន័យថា នៅពេលគេដេញតាមជនល្មើសបាននៅកន្លែងណាជាសមត្ថកិច្ចរបស់តុលាការនៅកន្លែងនោះ។

### ៣.៥ ចំណាត់ថ្នាក់ទៅតាមប្រភេទនៃអំពើជាសម្ភារៈ

ប្រភេទនៃអំពើជាសម្ភារៈនៃបទល្មើសមួយអាចជាការប្រព្រឹត្តសកម្មភាពណាមួយ ឬការមិនប្រព្រឹត្តសកម្មភាពណាមួយ។ ប្រសិនបើអំពើជាសម្ភារៈជាការប្រព្រឹត្តសកម្មភាពបទល្មើសនោះ គឺមានឈ្មោះថាជា**បទល្មើសសកម្ម** ។

ផ្ទុយទៅវិញប្រសិនបើអំពើជាសម្ភារៈជាការមិនប្រព្រឹត្តសកម្មភាព ឬអនុប្បវាទបទល្មើសនោះ គឺមានឈ្មោះថា **បទល្មើសអកម្ម**។

#### ៣.៥.១ បទល្មើសសកម្ម

**បទល្មើសសកម្ម** គឺជាអំពើសម្ភារៈ ឬជាសត្យានុម័តរបស់បទល្មើសដែលអាចជាសកម្មភាព

ពោលគឺជាអំពើវិជ្ជមានបានន័យថា ចារីនៃបទល្មើសបានប្រព្រឹត្តទង្វើណាមួយ ដែលច្បាប់បានហាមឃាត់។

**ឧទាហរណ៍៖**

- អំពើជាសត្យានុម័តនៃអំពើលួច គឺជាអំពើដកហូតយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ។
- អំពើជាសត្យានុម័តនៃបទប្រទូសកេរ្តិ៍ខ្មាស គឺជាអំពើប៉ះពាល់ស្ទាបអង្អែលកេរ្តិ៍ភេទ ឬផ្នែកភេទផ្សេងទៀតរបស់អ្នកដទៃ។

### ៣.៥.២ បទល្មើសអកម្ម

**បទល្មើសអកម្ម** គឺជាបទល្មើសដែលកើតចេញ ពីការបំពានកាតព្វកិច្ចដែលច្បាប់តម្រូវដូចជាការបំពេញកិច្ចជាវិជ្ជមានមួយដូចជាៈ កាតព្វកិច្ចផ្តល់ព័ត៌មានអំពីបទល្មើស និងការដោះបន្ទុក និងបង្ហាញភស្តុតាងពីភាពស្លូតត្រង់របស់ជនដែលស្ថិតនៅក្នុងដំណាក់កាលនីតិវិធីតុលាការ។ មូលហេតុនៃការបង្កើតបទល្មើសអកម្មមានពីរយ៉ាងគឺ៖

- បង្កើតការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានាដើម្បីស្វែងរក និងបង្ក្រាបបទល្មើស។
- បង្កើតសាមគ្គីភាពក្នុងសង្គមក្នុងគោលដៅរួមចំណែករក្សាសន្តិសុខភាពស្ងប់ស្ងាត់។

**ឧទាហរណ៍ៈ** មាត្រា៣២៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ចាត់ទុកថាជាបទល្មើសមិនព្រមប្រគល់អនីតិជន ចំពោះអំពើប្រព្រឹត្តដោយគំនិតទុច្ចរិត ដែលមិនព្រមប្រគល់អនីតិជនឲ្យទៅបុគ្គលដែលមានសិទ្ធិទាមទារនោះ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១ខែ ទៅ ១ឆ្នាំ** និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ២លានរៀល។

មាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌ ចាត់ទុកជាបទល្មើស ចំពោះការមិនប្តឹងបរិហារបទឧក្រិដ្ឋ ដោយបានចែងថា រាល់បុគ្គលណាដែលបានដឹងពីបទឧក្រិដ្ឋ ដែលអាចនឹងបង្ការ ឬបន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនប្តឹងបរិហារ ដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ២លានរៀល។

មាត្រា៥៣០ នៃក្រមព្រហ្មទណ្ឌ ចាត់ទុកជាបទល្មើស ចំពោះការមិនប្តឹងបរិហារកេរ្តិ៍ ពីការធ្វើបាបអនីតិជនដោយចែងថារាល់បុគ្គលណាដែលបានដឹងពីការធ្វើបាប ឬការបៀតបៀនខាងផ្លូវភេទអនីតិជនអាយុក្រោម១៥ឆ្នាំ ហើយមិនបានប្តឹងបរិហារកេរ្តិ៍ អាជ្ញាតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល។

# ជំពូកទី៤

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

# ជំពូកទី៤ ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

## ៤.១ ការទទួលខុសត្រូវព្រហ្មទណ្ឌ

ជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះតែអំពើរបស់ខ្លួនតែប៉ុណ្ណោះ។[45] មានន័យថា នៅពេលដែលមានបទល្មើសមួយបានកើតឡើង ជនដែលប្រព្រឹត្តបទល្មើសត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន បើទោះបីជាស្ថិតនៅក្នុងឋានៈ ជាចារី ឬជាសហចារី ឬជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិតក៏ដោយ។ ក៏ប៉ុន្តែច្បាប់ក៏អាចអនុញ្ញាតអោយមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីបានផងដែរ ចំពោះអំពើរបស់អ្នកដទៃដូចជាៈ ការទទួលខុសត្រូវរបស់ឪពុកម្តាយ ចំពោះអំពើរបស់អនីតិជន ឬការទទួលខុសត្រូវរបស់និយោជកចំពោះអំពើរបស់និយោជិតជាដើម។[46] កាលណាបើមានធាតុផ្សំគ្រប់គ្រាន់ហើយបុគ្គលដែលបានប្រព្រឹត្តអំពើត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមច្បាប់កំណត់ បើទោះបីជារូបវន្តបុគ្គលក្តី និងជានីតិបុគ្គលក្តី។

### ៤.១.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល គឺជាអំពើប្រព្រឹត្តផ្ទាល់របស់បុគ្គលណាមួយហើយបុគ្គលនោះនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនៅអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ វាជារឿងដែលអយុត្តិធម៌ណាស់ ប្រសិនបើអោយជនដែលមិនបានប្រព្រឹត្តបទល្មើលព្រហ្មទណ្ឌមកទទួលខុសត្រូវនោះ។ និតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់យកត្រឹមអាយុ១៨ (ដប់ប្រាំបី)ឆ្នាំ។ ចំពោះការចោទប្រកាន់ពីបទព្រហ្មទណ្ឌនីមួយៗ ចាំបាច់ត្រូវផ្ទៀងផ្ទាត់តួនាទីដ៏ត្រឹមត្រូវរបស់អ្នកចូលរួមប្រព្រឹត្តបទល្មើសនីមួយៗ។

អាស្រ័យទៅលើធាតុទាំងឡាយនៃសំណុំរឿងរបស់អ្នកចូលរួមទាំងនោះ គឺអាចត្រូវបានកំណត់ប្រភេទគតិយុត្តជាចារី ឬសហចារី ឬអ្នកផ្តើមគំនិត ឬអ្នកសមគំនិត។ ម្យ៉ាងទៀតប្រសិនបើបទល្មើសបានទៅដល់គោលបំណងហើយ គេនិយាយថាបទល្មើសនេះបានសម្រេច។

#### ក.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន គឺមានន័យថាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ជននោះនឹងត្រូវទទួលខុសត្រូវនៅអំពើដែលខ្លួនបានប្រព្រឹត្ត នៅចំពោះមុខច្បាប់ដោយគ្មានការយោគយល់និងការលើកលែងឡើយ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជនស្តែងឡើងតាមរូបភាពដូចខាងក្រោមៈ

---

[45] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៥។

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧៤៦-៧៤៧។

- **ចារី** គឺបុគ្គលណា ដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលមួយណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម។[47] តាមរយៈនេះបញ្ជាក់ឲ្យឃើញពីសញ្ញាណនៃចារី គឺជាបុគ្គលដែលសម្រេចបំណងរបស់ខ្លួន ដោយការប្រព្រឹត្តបទល្មើសមួយបានសម្រេចព្រមទាំងបុគ្គល ដែលប៉ុនប៉ងប្រព្រឹត្តបទល្មើស ហើយនេះគឺជាករណីនៃការប៉ុនប៉ង។ ចារីនៃការប៉ុនប៉ងត្រូវបានគេប្រដូចទៅនឹងចារីនៃបទល្មើសបានសម្រេចដែរ។ ប៉ុន្តែសម្រាប់ចារីនៃការប៉ុនប៉ងក្នុងបទមជ្ឈិម គឺទាល់តែមានច្បាប់ចែងយ៉ាងជាក់លាក់ទើបអាច ផ្តន្ទាទោសដូចជាចារីនៃបទមជ្ឈិមបានសម្រេចដែរ។
- **សហចារី** គឺបុគ្គលច្រើននាក់បានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ត្រូវចាត់ទុកជាសហចារីផងដែរ។ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។[48] សញ្ញាណនៃសហចារីនេះ គឺយោងទៅដល់ការចូលអន្តរាគមន៍របស់រូបវន្តបុគ្គលជាច្រើនរូប នៅក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តបទល្មើស ដោយបុគ្គលទាំងនោះបានចូលរួមអន្តរាគមន៍ជាមួយនឹងកម្រិតនៃការទទួលខុសត្រូវដូចគ្នានៅក្នុងសកម្មភាព។ ក្រៅពីចារី និងសហចារី បុគ្គលផ្សេងទៀតអាចចូលរួមក្នុងការប្រព្រឹត្តបទល្មើសផងដែរ។
- **អ្នកផ្តើមគំនិត** គឺបុគ្គលជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬការបញ្ជារបស់ខ្លួន ឬបុគ្គលដែលបង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្តល់អំណោយដោយការសន្យា ឬការគំរាមកំហែង ឬការញុះញង់ ឬការលួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ ទាល់តែបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលចារីបានប្រព្រឹត្តបានសម្រេច ឬបានប៉ុនប៉ងទើបអ្នកផ្តើមគំនិតត្រូវផ្តន្ទាទោសដូចគ្នានឹងចារីប្រព្រឹត្តបទល្មើស។[49]
- **អ្នកសមគំនិត** គឺបុគ្គលដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋឬបទមជ្ឈិមដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតក៏មានសញ្ញាណដូចគ្នានឹងអ្នកផ្តើមគំនិតដែរ។ មានន័យថា ទាល់តែចារីបាន

[47] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៥។
[48] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៦។
[49] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៨។

ប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេច ឬប៉ុនប៉ង។[50]

**ខ.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**

ជាគោលការណ៍ គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ប្រសិនបើក្មេងមានអាយុ៥ឆ្នាំ ម្នាក់បានចាក់សម្លាប់ក្មេងម្នាក់ទៀត ហើយក្មេងដែលបានប្រព្រឹត្តអំពើល្មើសនោះ គឺមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ពីព្រោះដោយសារតែក្មេងម្នាក់នោះមានអាយុ៥ឆ្នាំ ដូច្នេះក្មេងម្នាក់នោះ គឺមិនអាចមានសមត្ថភាពដឹងខុសត្រូវ ចំពោះអំពើរបស់ខ្លួនឡើយ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ។[51] ដូចនេះមានន័យថាអនីតិជនដែលមានអាយុតិចជាង១៤ឆ្នាំ គឺមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។ បើទោះបីជាអនីតិជនដែលបានប្រព្រឹត្តបទល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌតម្រូវអោយមានវិធានការដែលជាកម្មវត្ថុ ក្នុងការតាមដានវិធានការអប់រំ, វិធានការការពារ និងវិធានការឧបត្ថម្ភ ហើយមិនត្រឹមតែប៉ុណ្ណោះទេ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ ប្រសិនការបើកាលទេសនៃបទល្មើស ឬបុគ្គលិកលក្ខណរបស់អនីតិជនតម្រូវ។[52]

**ខ.១. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស**

ក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើស គឺត្រូវស្ថិតនៅក្រោម ការការពាររបស់តុលាការ គឺតុលាការចាត់តាំងបុគ្គលមួយរូបឲ្យទទួលភារៈធ្វើការតាមដានអនីតិជនរូបនេះ។ បុគ្គលរូបនេះត្រូវផ្ញើរបាយការណ៍ស្តីពីកិរិយាមាយាទរបស់អនីតិជនឲ្យបានទៀងទាត់ ដល់ព្រះរាជអាជ្ញា។ បុគ្គលនោះត្រូវផ្តល់ព័ត៌មានទាំងអស់ដែលក្នុងរយៈពេល នៃការតាមដានរបស់ខ្លួនទៅដល់ព្រះរាជអាជ្ញា ដើម្បីអាចនាំអោយមានការកែតម្រូវនូវវិធានការខ្លះ ចំពោះបុគ្គលិកលក្ខណៈរបស់អនីតិជននោះ។[53]

ប្រភេទនៃវិធានការតាមដាន, វិធានការអប់រំ, វិធានការការពារ និងវិធានការឧបត្ថម្ភ[54] រួមមានដូចតទៅ ៖

- ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ ឬអាណាព្យាបាល ឬបុគ្គលដែលអាចថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។

[50] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៩។
[51] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨។
[52] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩។
[53] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤១ ។
[54] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩ ។

- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួល។
- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។
- ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

តុលាការជាស្ថាប័នមានសមត្ថកិច្ច ក្នុងការចាត់វិធានការដែលបានរៀបរាប់នៅមាត្រា៤០ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ គឺពុំបានចែងលំអិតអំពីនីតិវិធីពិសេសសម្រាប់ការចាត់វិធានការទាំងអស់នេះឲ្យមានប្រសិទ្ធិភាពនោះទេ។

### ខ.២. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន

សម្រាប់អនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ គឺតុលាការអាចប្រកាសទណ្ឌកម្មបាន។ ទណ្ឌកម្មព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌសំដៅដល់គឺ ទោស នេះតែម្តង។ ការកំណត់អាយុ ១៤ឆ្នាំ សម្រាប់លទ្ធភាពនៃការប្រកាសទណ្ឌកម្ម ស្របតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលអនុញ្ញាតឲ្យមានការឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទជាបណ្តោះអាសន្ន ។ ចំពោះអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ ១៨ឆ្នាំ ក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ និងថិរវេលា ក្នុងការឃុំខ្លួនបណ្តោះអាសន្ន។[55]

ចំណែកអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ វិញ គឺមិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ ក៏អនីតិជននោះមិនអាចឃុំខ្លួនបណ្តោះអាសន្នបានទេ ក៏ប៉ុន្តែចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះទៅអោយឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។[56] ក៏ប៉ុន្តែតុលាការអាចចាត់វិធានការណាមួយដូចមានចែងនៅមាត្រា៤០ នៃក្រមព្រហ្មទណ្ឌបាន។

ក្នុងករណីដែលអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដូចជា: បទឃាតកម្មជាដើម កាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះ អាចជាមូលហេតុឲ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនបាន។

ក្នុងករណីដែលអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅបានលួចស្បែកជើងមួយគូរ តើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះតម្រូវឲ្យតុលាការប្រកាសទោសលើអនីតិជនបានដែរឬទេ? ការដែលតុលាការត្រូវប្រកាសដាក់ទណ្ឌកម្មលើអនីតិជន ត្រូវបន្ថយក្នុងលក្ខខណ្ឌដូចមានចែងនៅមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

---

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១៣-២១៤។

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២១២។

- អតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល។
- ប្រសិនអតិបរមានៃទោសដាក់ពន្ធនាគារ គឺជាទោសដាក់ពន្ធនាគារ អស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ ឆ្នាំ។
- អប្បរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាលប្រសិនបើ អប្បបរមានេះលើសពី ១ថ្ងៃ។
- អប្បរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល។

### ៤.១.២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលជាក្រុមមនុស្ស ឬជាមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។[57] ជាទូទៅនីតិបុគ្គលមានពីរប្រភេទគឺ នីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិ។ នីតិបុគ្គលសាជីវកម្ម ជាក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចដោយឯករាជ្យ។[58] នីតិបុគ្គលមូលនិធិ ជាចំណែកទ្រព្យសម្បត្តិវិភាគទានដែលត្រូវបានប្រគល់នូវឋានជាប្រធានសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ។[59] នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស ដែលប្រព្រឹត្តដោយអង្គការអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមិនលើកលែងនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ក្នុងអំពើដដែលនោះទេ។ មិនត្រឹមតែក្រមព្រហ្មទណ្ឌទេ ដែលបានកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ក៏មានការកំណត់អំពីការទទួលខុសត្រូវនៅក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗទៀតដែរ។ **នីតិបុគ្គល** គឺមិនត្រឹមតែទទួលទោសទណ្ឌកម្មដូចដែលមានចែង ក្នុងក្រមព្រហ្មទណ្ឌនោះទេ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ក៏ចែងពីការដាក់ទោសនីតិបុគ្គលដែរ។ នៅពេលក្រុមហ៊ុនមួយ ផ្តល់សិទ្ធិឲ្យតំណាងរបស់ខ្លួន ឬបុគ្គលដឹកជញ្ជូននូវទំនិញដែលជាផលប្រយោជន៍របស់ខ្លួន ហើយបុគ្គលជាអ្នកបើកបរធ្វេសប្រហែស, ខ្ជីខ្ជា, មិនប្រុងប្រយ័ត្ន, មិនគោរពច្បាប់, បណ្តាលឲ្យអ្នកដទៃរបួស ឬអសមត្ថភាពប្រកបការងារ ឬបណ្តាលឲ្យស្លាប់ ក៏ត្រូវទទួលទោសទណ្ឌកម្មដែរ។

ច្បាប់ចរាចរណ៍ផ្លូវគោក មាត្រា៨៦ បានចែងថា នីតិបុគ្គលត្រូវប្រកាសទោសព្រហ្មទណ្ឌតាមលក្ខណ្ឌដូចដែលមានចែងក្នុងមាត្រា៤២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងមាត្រា៨៥ ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។

[57] ក្រមរដ្ឋប្បវេណី, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ២០០៧, លេខរៀងទី៧១។
[58] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា៤៦។
[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា៤៦។

នីតិបុគ្គលត្រូវផ្តន្ទាទោសជាប្រាក់ពី១០លានរៀល ទៅ៥០លានរៀល ហើយព្រមទាំងបន្ថែមទោសមួយ ឬច្រើនដូចខាងក្រោមនេះទៀត ៖

- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល។
- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។
- ការហាមឃាត់ធ្វើសកម្មភាពណាមួយ ឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ការហាមឃាត់ចំពោះធ្វើសកម្មភាព។
- ការបិទគ្រឹះស្ថានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសតាមបែបបទ កំណត់ដោយមាត្រា១៧៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ការបិទគ្រឹះស្ថាន។
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្ម លើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដល់សាធារណជន តាមបែបបទកំណត់ដោយក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រ១៧៧ ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបកំណត់ដោយក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា១៨០ ការបិទសេចក្តីសម្រេច។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មានសរសេរ ឬផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ តាមបែបកំណត់ដោយក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា១៨១ ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍។

កាលបើលក្ខខណ្ឌដែលកំណត់ដោយច្បាប់មានគ្រប់គ្រាន់ហើយ នីតិបុគ្គលនឹងត្រូវប្រកាសថាត្រូវទទួលទោសព្រហ្មទណ្ឌបាន ហើយនឹងត្រូវទទួលទណ្ឌកម្មដូចដែលមានចែងនៅក្នុងច្បាប់។ បើមានបទបញ្ញត្តិពិសេសសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលក្តី ក៏ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុត្រូវកំណត់ដោយយោងទៅតាមទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល។[60]

[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៨។

### ក. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលគ្រប់ប្រភេទសុទ្ធតែអាចទទួលខុសត្រូវព្រហ្មទណ្ឌ រួមទាំងនីតិបុគ្គលសាធារណៈផង។ ប៉ុន្តែរដ្ឋដែលជានីតិបុគ្គលសាធារណៈ គឺពុំទទួលខុសត្រូវព្រហ្មទណ្ឌទេ។[61] នីតិបុគ្គលដែលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌបាន គឺលុះត្រាតែមានច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗទៀតបានចែងទុកជាមុនអំពីអត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ហើយបទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល និងការប្រព្រឹត្ត ដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល។

### ក.១ អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត

នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌកាលបើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានចែងយ៉ាងច្បាស់ថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ បទល្មើសណាមួយជាកំណត់។ មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ អំពីបទឃាតកម្ម គឺក្រមព្រហ្មទណ្ឌមិនបានចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលទេ មានន័យថា នីតិបុគ្គលមិនអាចត្រូវបានប្រកាសថា ទទួលខុសត្រូវព្រហ្មទណ្ឌពីបទឃាតកម្មបានឡើយ។

### ក.២ បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល

**នីតិបុគ្គល** គឺជាបុគ្គលដែលកើតឡើងពីការសន្មតរបស់ច្បាប់។ នីតិបុគ្គលរមែងមានអង្គការតំណាងក្រោមរូបភាពជាក្រុមប្រឹក្សា ឬអ្នកតំណាងរូបវន្តបុគ្គល ដែលធ្វើសកម្មភាពតំណាងឲ្យនីតិបុគ្គលជានិច្ច។

### ក.៣ ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល

គឺមានតែការប្រព្រឹត្តបទល្មើស ដើម្បីជាផលប្រយោជន៍ដល់នីតិបុគ្គលតែប៉ុណ្ណោះ ដែលជាកត្តាធ្វើឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ។ ឧទាហរណ៍: ប្រសិនបើក្រុមហ៊ុនមិនចាត់វិធានការឲ្យបានត្រឹមត្រូវ ហើយធ្វើឲ្យកម្មករស្លាប់បាត់ បង់ជីវិត នោះអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុននឹងត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទមនុស្សដោយអចេតនាបាន។

### ខ. ការដាក់ទណ្ឌកម្មលើនីតិបុគ្គល

ក្រមព្រហ្មទណ្ឌ បានកំណត់ពីទោសទាំងឡាយសម្រាប់នីតិបុគ្គលរួមមានៈ

- ទោសពិន័យក្នុងឋាន:ជាមូលទោស។
- ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ។

ទោសបន្ថែមសម្រាប់នីតិបុគ្គលអាចប្រកាសដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់។

[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤២។

ទោសបន្ថែមសម្រាប់អនុវត្តលើនីតិបុគ្គលមានរួមមានដូចខាងក្រោមៈ

- ការរំលាយចោល។
- ការដាក់នៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។
- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន។
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។
- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។
- ការហាមឃាត់ចំពោះឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរ ឬបានដែលកំណត់ដោយធនាគារ។
- ការហាមឃាត់ចំពោះការប្រើប័ណ្ណទូទាត់។
- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស។
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណៈជន ឬដែលបានប្រើប្រាស់ដោយសាធារណៈជន ។
- ការរឹមអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់ ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុក្នុងទីកន្លែង ដែលបទល្មើសបានប្រព្រឹត្ត។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមទូរគមនាគមន៍សោតទស្សន៍។

## ៤.២ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ បណ្តាលមកពីមូលហេតុណាមួយដែលច្បាប់ព្រហ្មទណ្ឌចាត់ទុកថា ជាមូលហេតុត្រឹមត្រូវ។ ហើយក៏មានករណីខ្លះដែលច្បាប់មិនតម្រូវឲ្យអ្នកប្រព្រឹត្តទទួលខុសត្រូវព្រហ្មទណ្ឌដែរ ដោយហេតុថា អ្នកប្រព្រឹត្តបទព្រហ្មទណ្ឌ គឺមានអាយុតិចជាងការកំណត់របស់ច្បាប់ ឬមានបញ្ហាវិបល្លាសស្មារតីជាដើម។

### ៤.២.១ មូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌតាមក្រមព្រហ្មទណ្ឌរួមមានៈ

### ក. វិបល្លាសស្មារតី

**វិបល្លាសស្មារតី** គឺសំដៅដល់វិបត្តិដែលធ្វើអោយមានភាពមិនត្រឹមត្រូវ ដល់សកម្មភាពសរសៃប្រសាទរបស់មនុស្សដែលបាត់បង់ការដឹងខុសត្រូវ។ វិបល្លាសស្មារតីអាចបណ្តាលមកពីភាពជរាគ្រោះថ្នាក់ដោយសារហេតុការណ៍ណាមួយ ការធ្វើទារុណកម្ម ឬបណ្តាលមកពីជម្ងឺណាមួយជាដើម។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ដោយសារតែប្រព័ន្ធសរសៃប្រាសាទមានសកម្មភាពមិនប្រក្រតី ចារីបានបាត់បង់នូវលទ្ធភាពការយល់ដឹងពីពិភពខាងក្រៅជុំវិញខ្លួន ហើយពុំអាចត្រួតពិនិត្យសកម្មភាពរបស់ខ្លួនបាន ផ្ទុយទៅវិញប្រសិនបើជនណា

ម្នាក់បានប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដោយសារ ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬសារធាតុដែលច្បាប់បានហាមឃាត់ គឺមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។[62]

ជាទូទៅភស្តុតាងនៃវិបល្លាសស្មាតីត្រូវបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញ ក៏ប៉ុន្តែយោបល់ទាំងនោះ គឺពុំមានអានុភាពចងជាកាតព្វកិច្ចឲ្យចៅក្រមត្រូវតែជឿតាមទេ ពោលគឺចៅក្រមអាចជឿក៏បាន មិនជឿក៏បាន។

### ខ. កម្លាំង ឬការបង្ខំ

កម្លាំង និងការបង្ខំ គឺអាចចេញមកពីការធ្វើក្រៅឆន្ទៈរបស់បុគ្គលតែប៉ុណ្ណោះ ហើយកម្លាំងនៃការបង្ខំ គឺមិនអាចដឹងមុនបានឡើយ។ បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនោះមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទរបស់មនុស្សតែប៉ុណ្ណោះ ហើយកម្លាំង និងការបង្ខំនេះ គឺមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបានទេ។[63] កាលបើមានភស្តុតាងថា មានកំលាំងអ្វីមួយបានបង្ខំជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះកាលបើ មិនអាចទប់ទល់នឹងកំលាំងនោះបានទេ ក៏ប្រព្រឹត្តបទល្មើសនោះទៅ ។ ជនប្រព្រឹត្តបទល្មើសនេះមិនត្រូវឲ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ ។

#### ខ.១ ការបង្ខំលើរូបកាយ

ការបង្ខំមកលើរូបរាងកាយពីកម្លាំងពីខាងក្រៅ ដែលធ្វើអោយចារីមិនអាចឃាត់ឃាំងអំពើដែលខ្លួនបានធ្វើនោះបានឡើយ។ កម្លាំងបង្ខំអាចជាកម្លាំងបង្ខំមកពីខាងក្រៅដូចជាកម្លាំងបង្ខំមកពី

[62] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣១។

[63] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៦។

ព្រឹត្តិការណ៍ធម្មជាតិមកពីសត្វ ឬមកពីតតិយជនណាមួយ ឬម៉្យាងវិញទៀតអាចបណ្តាលមកពីកម្លាំងបង្ខំ មកពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារីដូចជា: ការធ្វើតាមសេចក្តីសម្រេចរបស់តុលាការដែលចារីផ្ទាល់ដោយសារតែ កត្តាសុខភាព និងគ្រោះថ្នាក់ផ្សេងៗ។

**ខ.២ ការបង្ខំលើផ្លូវចិត្ត**

ការបង្ខំលើផ្លូវចិត្តសំដៅលើកម្លាំងដែលបង្ខំឆន្ទៈរបស់ចារី។ ការបង្ខំផ្លូវចិត្ត ក៏អាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ ការបង្ខំនេះមានប្រភពមកពីព្រឹត្តការណ៍ក្រៅឆន្ទៈរបស់ចារី។ ជម្រុញឲ្យចារីមិនអាចបញ្ចៀសបានពីការប្រព្រឹត្តបទល្មើស។

**គ. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ**

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់បុគ្គលនោះ គឺមិនប្រព្រឹត្តបទល្មើសទេ។ ហើយបុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះ គឺមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។[64] មាត្រា៩៩ នៃក្រមព្រហ្មទណ្ឌចាស់បានចែងថា មិនទុកជាអំពើល្មើសក្នុងបទព្រហ្មទណ្ឌទេ កាលណាបើអំពើទាំងឡាយនោះធ្វើតាមបង្គាប់ច្បាប់ ហើយអ្នកបញ្ជាឲ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូបដែរ។ ក្នុងមាត្រា១០០ នៃក្រមព្រហ្មទណ្ឌចាស់ដដែលបានបញ្ជាក់បន្ថែមថា ក្នុងករណីដែលមានសេចក្តីបង្គាប់ជា អនីត្យានុកូល ហើយអ្នកបញ្ជាជាអាជ្ញាធរធម្មានុរូបនោះ ចៅក្រមត្រូវថ្លឹងថ្លែងមើលតាមការគួរនូវភាពនៃការទទួលខុសត្រូវ ក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអ្នកសម្រេចការនោះផង ។

**គ.១ ការអនុញ្ញាតដោយច្បាប់**

ក្នុងករណីនេះច្បាប់បញ្ញត្តិ ឬអនុញ្ញាតឲ្យប្រព្រឹត្តអំពើណាមួយ ហើយច្បាប់មិនអនុញ្ញាតឲ្យផ្តន្ទាទោសលើអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ចតម្រូវដោយច្បាប់ ។

**គ.២ ការអនុញ្ញាតដោយអាជ្ញាធរ**

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់បុគ្គលនោះ គឺមិនត្រូវចាត់ទុកថាប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះ ជាអំពើខុសច្បាប់ ។

**គ.៣ អាជ្ញាធរស្របច្បាប់**

អាជ្ញាធរស្របច្បាប់ គឺសំដៅដល់អាជ្ញាធរសាធារណៈ ដែលជាអាជ្ញាធររដ្ឋបាលឬអាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ ក្នុងការបញ្ជាឲ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ។

[64] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២។

### គ.៤ បញ្ជាស្របច្បាប់

ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យជនដែលប្រព្រឹត្តបទល្មើស តាមបញ្ជារបស់អាជ្ញាធរស្រប ច្បាប់ឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់។

### ឃ. ការការពារស្របច្បាប់

ជាការពិតនៅក្នុងគ្រប់ស្ថានភាពនៃអំពើនៃការបង្ខិតបង្ខំ ការគំរាមកំហែង ឬជាអំពើដែលបានដាក់សំពាតទៅលើបុគ្គលណាម្នាក់ ច្បាស់ណាស់បុគ្គលនោះនឹងបញ្ចេញកម្លាំង ក្នុងការតបតវិញនៅក្នុងស្ថានភាពនៃការការពារខ្លួន។ បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[65] វាច្បាស់ណាស់ថានៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើដែលច្បាប់ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារខ្លួនឯង ឬអ្នកដទៃ ឬទ្រព្យសម្បត្តិពីអំពើឈ្លានពានណាមួយ របស់បុគ្គលផ្សេងទៀតបុគ្គលនោះ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ផ្ទុយទៅវិញប្រសិនបើ មានការដាក់ទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើសដើម្បីការពារខ្លួននោះ វាជារឿងមួយដែលអយុត្តិធម៌បំផុត។ លក្ខខណ្ឌនៃការការពារស្របច្បាប់រួមមានដូចខាងក្រោម ៖

- បទល្មើសត្រូវចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការពារឈ្លានពានមួយ ដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

### ឃ.១ លក្ខខណ្ឌនៃការការពារស្របច្បាប់

ការឈ្លានពាន និងការការពារត្រូវមានលក្ខណៈមួយចំនួន ដើម្បីការការពារក្លាយជាយុត្តិកម្មនៃបទល្មើស។

#### ឃ.១.១ ការឈ្លានពាន

ការឈ្លានពានត្រូវកើតឡើងមុនពេលមានការការពារ ពីព្រោះថាអំពើការពារធ្វើឡើងដោយការចាំបាច់ដើម្បីការពារប្រឈមមុខនឹងការឈ្លានពានណាមួយ។ ការឈ្លានពាន គឺជាធាតុផ្សំចាំបាច់នៃការការពារស្របច្បាប់។ ការឈ្លានពាននេះអាចធ្វើទៅលើទ្រព្យសម្បត្តិ ឬរូបកាយរបស់អ្នកការពារផ្ទាល់ ឬទៅលើតតិយជនក៏បានដែរ។

---

[65] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៣។

### ឃ.២.២ ការការពារឈ្លានពាន

ការការពារទៅនឹងអំពើឈ្លានពានណាមួយ គឺស្តែងឡើងតាមរយៈការតបតពីសំណាក់ជនដែលទទួលរងនូវការឈ្លានពាននោះ។ អំពើការពារអាចជារូបភាពប្លែកៗពីគ្នាដូចជាៈ ការសម្លាប់ ការប្រើហិង្សា ជាដើម។ ការប្រព្រឹត្តអំពើខ្លះមិនត្រូវបានចាត់ទុកថា ជាអំពើការពារនៃការការពារស្របច្បាប់នោះឡើយដូចជាៈ ការរំលោភសេពសន្ថវៈ ឬការធ្វើទារុណកម្ម ជាដើម។ ការការពារត្រូវមានលក្ខណដូចតទៅៈ

- ការការពារត្រូវតែកើតឡើង ក្នុងពេលជាមួយគ្នានឹងការឈ្លានពាន គឺមានន័យថាការការពារត្រូវតែធ្វើឡើងភ្លាមៗ ក្នុងខណៈដែលការឈ្លាន ពានបានកើតឡើង។ បើការការពារខ្លួនមិនបានធ្វើឡើងក្នុងពេលនៃអំពើនោះទេ តែបានធ្វើការឆ្លើយតបនៅពេលក្រោយ នេះមិនត្រូវបានចាត់ទុកជាការការពារខ្លួននោះទេ តែចាត់ទុកជាការសងសឹកទៅវិញ។
- ការការពារត្រូវតែចាំបាច់ សម្រាប់ស្រោចស្រង់ដល់ផលប្រយោជន៍ ដែលត្រូវបានគំរាមកំហែង គឺមានន័យថាការការពារត្រូវតែជាការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ។ ប្រតិកម្មរបស់អ្នកការពារ គឺជាមធ្យោបាយតែមួយគត់ដើម្បីបញ្ចៀសការឈ្លានពាន។
- មធ្យោបាយការពារដែលប្រើប្រាស់ ត្រូវតែគ្មានវិសមាមាត្រជាមួយនឹងទម្ងន់នៃការឈ្លានពានមធ្យោបាយ គឺមានន័យថាការការពារដែលបានប្រើប្រាស់ត្រូវតែឆ្លើយតបទៅនឹងភាពធ្ងន់ធ្ងរ នៃការឈ្លានពានមិនត្រឹមត្រូវ។ កាលបើអំពើមួយត្រូវបានចាត់ទុកថាជាការការពារស្របច្បាប់ហើយ ចារីមិនត្រឹមតែមិនទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះទេ គឺថែមទាំងត្រូវទទួលខុសត្រូវរដ្ឋប្បវេណីទៀតផង។[66]

### ខ. ស្ថានភាពចាំបាច់

ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយ ដោយសារតែមានបំណងចង់ជួយស្តារនូវផលប្រយោជន៍ មួយផ្សេងទៀតដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន ។

ចំពោះស្ថានភាពចាំបាច់ ចារីមានជម្រើសពីរយ៉ាងគឺ ៖

- ទទួលយកការខូចខាតដែលនឹងត្រូវកើតមានឡើង ដោយសុខចិត្តបដិសេធមិនព្រមប្រព្រឹត្តបទល្មើស។
- ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត

[66] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧៥៥។

ស្ថានភាពចាំបាច់ត្រូវបានចាត់ទុកថាជាយុត្តិកម្មនៃបទល្មើស តាមមាត្រា៣៥ នៃក្រមព្រហ្មទណ្ឌ បានចែងថា បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស នោះគឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខណៈ ដូចខាងក្រោមនេះ៖

- បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។

**ខ.១ គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន**

ជនដែលប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ ត្រូវរកភស្តុតាងអំពីគ្រោះថ្នាក់ ដែលជម្រុញឲ្យប្រព្រឹត្តបទល្មើស។ ឧទាហរណ៍: ដើម្បីកុំឲ្យកូនស្លាប់ដោយអត់អាហារម្តាយបានសម្រេចចិត្តលួចបាយ ឬ អង្ករយកមកចំអិនដើម្បីចិញ្ចឹមកូន។ នេះគឺជាការបញ្ចៀសពីគ្រោះថ្នាក់ដល់អាយុជីវិតកូនរបស់ចារីដែលបានប្រព្រឹត្តអំពើលួច។ ឧទាហរណ៍: បុរសម្នាក់បានដុតសំបុកឃ្មុំចោលរបស់អ្នកជិតខាង តែតាមពិតឃ្មុំមិនបានទិចទេ គឺជាគ្រោះថ្នាក់ដោយយថាហេតុ។ ការដុតសំបុកឃ្មុំ គឺមិនត្រូវផ្តន្ទាទោសនោះទេ ។

**ខ.២ ការការពារជាចាំបាច់**

ដើម្បីឲ្យមានយុត្តិកម្មបទល្មើសដែលប្រព្រឹត្តដោយចារី គឺត្រូវតែជាអំពើចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ។ ត្រង់ចំណុចនេះ គឺមានន័យថា ការប្រព្រឹត្តបទល្មើសជាជម្រើសដ៏ប្រសើរបំផុត និងជាជម្រើសតែមួយគត់ដើម្បីបញ្ចៀសគ្រោះថ្នាក់បាន។ ឧទាហរណ៍: នារីម្នាក់បានសម្រេចចិត្តលួចសាច់គោគេ ដើម្បីឲ្យកូនរបស់នាងបានបរិភោគអាហារដើម្បីចម្អែតក្រពះ។

**ខ.៣ ការការពារដែលគ្មានវិសមាមាត្រជាមួយនឹងទម្ងន់គ្រោះថ្នាក់**

ចារីត្រូវរកភស្តុតាងមកបង្ហាញឲ្យឃើញច្បាស់ថា បទល្មើសដែលខ្លួនបានប្រព្រឹត្តមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរ នៃគ្រោះថ្នាក់។ ផលវិបាកនៃបទល្មើសត្រូវតែមានតម្លៃតិចជាង ឬស្មើនឹងតម្លៃដែលចារីមានបំណងចង់ជួយស្រោចស្រង់សង្គ្រោះ។ ឧទាហរណ៍: អំពើរបស់អ្នកបើកបររថយន្តម្នាក់ បានសម្រេចបើកបររថយន្តរបស់គាត់ទៅប៉ះជញ្ជាំងផ្ទះរបស់តតិយជន ក្នុងគោលបំណងដើម្បីបញ្ចៀសការ ប៉ះទង្គិចដល់អ្នកថ្មើរជើងម្នាក់ ក្នុងករណីនេះគួរតែចាត់ទុកស្ថានភាពចាំបាច់ដែលមានលក្ខណៈសមាមាត្រ។ ក្នុងន័យនេះ អ្នកបើកបររថយន្តមិនត្រូវទទួលខុសត្រូវ ពីបទធ្វើឲ្យខូចខាតដោយចេតនាឡើយ ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវនូវប្រធានបទស្តីពីៈ បទល្មើសព្រហ្មទណ្ឌ រួចមកស បញ្ជាក់ឲ្យឃើញថា ការកំណត់បទល្មើសព្រហ្មទណ្ឌ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការ រក្សាឲ្យបាននូវភាពសុខសុវត្ថិភាព និងស្ថេរភាពនយោបាយដល់សង្គម។ ដើម្បីកំណត់ថាជាបទ ល្មើសមួយបាន គឺលុះត្រាតែមានធាតុផ្សំគ្រប់គ្រាន់ នោះទើបអាចចាត់ទុកថាជាបទល្មើសមួយបាន។ ហើយធាតុផ្សំនៃបទល្មើសនោះ រួមមានដូចជា: (១) ធាតុនីត្យានុកូល, (២) ធាតុសត្យានុម័ត, និង(៣) ធាតុអន្តោម័ត ។ ផ្ទុយទៅវិញប្រសិនបើពុំមានធាតុផ្សំគ្រប់គ្រាន់នោះទេ នោះគេពុំអាចចាត់ទុកថា ជា បទល្មើសមួយបានទេ (ក្នុងចំណោមធាតុផ្សំទាំងបី ខាងលើ ប្រសិនបើខ្វះនូវធាតុផ្សំណាមួយនោះ គឺ ពុំអាចចាត់ទុកថាជាបទល្មើសមួយបានទេ) ។ មួយវិញទៀតសោតទាក់ទងទៅនឹងចំណាត់ថ្នាក់នៃ បទល្មើសចំពោះចំណាត់ថ្នាក់នៃបទល្មើសក៏មានសារៈសំខាន់ណាស់ដែរ។ ការបែងចែកនូវចំណាត់ ថ្នាក់នៃបទល្មើស គឺពិតជាមានសារៈសំខាន់ណាស់ ក្នុងបែងចែកនូវបទល្មើសនីមួយៗ។ ហើយចំ ណាត់ថ្នាក់នៃបទល្មើសនោះ រួមមានដូចជា: (១) បទឧក្រិដ្ឋ, (២) បទមជ្ឈិម, និង(៣) បទលហុ។ ក្នុង ករណីនេះប្រសិនបើ គេពុំបានបែងចែកនូវចំណាត់ថ្នាក់នៃបទល្មើសនោះទេ គឺវាមានភាពរញ៉េរញ៉ៃ ខ្លាំង ក្នុងចោទប្រកាន់បទល្មើស ពីព្រោះបទល្មើសនីមួយៗ គឺវាពុំដូចគ្នានោះទេ ដោយហេតុថា មាន បទល្មើសខ្លះមានស្ថានទម្ងន់ទោសស្រាល និងបទល្មើសខ្លះមានស្ថានទម្ងន់ទោសធ្ងន់ធ្ងរ។ ដូច្នេះ បានជាគេបែងចែកនូវចំណាត់ថ្នាក់នៃបទល្មើសនេះឡើង។

ជាចុងបញ្ចប់ប្រធានបទមួយនេះ គឺចង់បង្ហាញថា បទល្មើសព្រហ្មទណ្ឌ គឺមានសារៈសំខាន់ ខ្លាំងណាស់ ក្នុងធានាឲ្យបាននូវសុខសុវត្ថិភាព និងស្ថេរភាពនយោបាយសង្គម ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើរួចមក យើងសង្កេតឃើញថា ដើម្បីអោយការអនុវត្តបទល្មើសមួយបានត្រឹមត្រូវ ចាំបាច់ណាស់ត្រូវតែអនុវត្តទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងខ្លឹមសារច្បាប់។ នៅពេលដែលមានបទល្មើសមួយបានកើតឡើង ជនដែលប្រព្រឹត្តបទល្មើសត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនទោះស្ថិតនៅក្នុងឋានជាចារី ជាសហចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិតក្តី។ កាលបើមានធាតុផ្សំគ្រប់គ្រាន់ហើយជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

ជាការពិតណាស់ច្បាប់បានចែងយ៉ាងលំអិតអំពីបទល្មើស និងទោសទៅលើជនដែលបានប្រព្រឹត្តបទល្មើស ដើម្បីធានាកុំអោយខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ឬអំពើប្រឆាំងនឹងមនុស្ស អំពើដែលប៉ះពាល់នៃបូរណភាពនៃបុគ្គល ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ សេរីភាព ឬសិទ្ធិរបស់មនុស្ស អំពើបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ លួច ឆក់ ប្លន់ជាដើម។ បើទោះបីជាច្បាប់បានចែងយ៉ាងលំអិតយ៉ាងណាក៏ដោយ អ្វីដែលសំខាន់ គឺការអនុវត្តផ្ទាល់ដើម្បីធានាបានថាជនដែលបានប្រព្រឹត្ត គឺត្រូវទទួលទោសទៅតាមទំហំនៃអំពើរបស់ខ្លួន។ ម្យ៉ាងវិញទៀតការប្រតិបត្តិរបស់ភ្នាក់ងារអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងតុលាការ ត្រូវតែធ្វើការពិនិត្យវិនិច្ឆ័យអោយបានត្រឹមត្រូវ ចំពោះការគោរពតាមច្បាប់ជាតិ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ដើម្បីធានាអោយការអនុវត្តច្បាប់របស់មន្ត្រីមានសមត្ថកិច្ចកាន់តែមានប្រសិទ្ធភាពនោះ គឺត្រូវតែះ

- ចៅក្រមត្រូវតែរក្សាភាពមិនលំអៀង និងចៀសវាងការវិនិច្ឆ័យរឿងក្តីមុនសេចក្តីសម្រេច។
- ពង្រឹងការអនុវត្តនីតិវិធីនៅគ្រប់ដំណាក់កាល និងធានាការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលធ្វើឡើងដោយតុលាការមានសមត្ថកិច្ចឯករាជ្យ និងឥតលំអៀង។
- ពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ជាពិសេសចំពោះការឃាត់ខ្លួន ចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយ។
- មន្ត្រីសាធារណៈ ( រួមមានមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា ) ត្រូវធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងភាពមាន ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទណាម្នាក់ មុនពេលបើកកិច្ចជំនុំជម្រះក្តីត្រូវបានបញ្ចប់ជាស្ថាពរ។
- ពង្រឹងវិស័យអប់រំ កាត់បន្ថយអត្រាការបោះបង់ចោលការសិក្សា និងលើកទឹកចិត្តអោយឪពុកម្តាយបញ្ជូនកូនៗទៅសិក្សាអោយបានគ្រប់ៗគ្នា។

- ពង្រឹងនឹងផ្សព្វផ្សាយច្បាប់ទៅអោយពលរដ្ឋ លើកកម្ពស់ការអានសៀវភៅ និងការចូលរួមនៅក្នុងកិច្ចការងារសង្គម។

ជារួមមកយើងមិនចង់ឃើញប្រទេសដែលមានច្បាប់ល្អ ហើយពលរដ្ឋប្រព្រឹត្តតែអំពើល្មើសនោះទេ ការយល់ដឹងរបស់ប្រជាពលរដ្ឋពិតជាមានសារសំខាន់ណាស់ក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិអោយមានការរីកចម្រើន។

# ឯកសារយោង

- **លិខិតបទដ្ឋានគតិយុត្តនានា**
  - ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ សីហា ២០០៩។
  - ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ សីហា ២០០៧។
  - ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ធ្នូ ២០០៧។
  - កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ចុះថ្ងៃទី១៦ ធ្នូ ១៩៦៦។
- **ឯកសារដែលចងក្រងជាសៀវភៅ និងឯកសារសិក្សាផ្សេងៗទៀត**
  - សៀវភៅសាស្ត្រាចារ្យ ហ៊ាង ឡេង នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០១០។
  - សៀវភៅសាស្ត្រាចារ្យ សេង ស៊ីវិត្ថា នីតិព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០១៣។
  - សៀវភៅសាស្ត្រាចារ្យ សែ វ៉េង នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១៣។

# ឧបសម្ព័ន្ធ